


សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស
លីកាដូ

LICADHO

Cambodian League for the Promotion and Defense of Human Rights


# ចំណងក្នុងឡឥដ្ឋ

## ឱកាសដើម្បីបញ្ចប់ការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារ ក្នុងសិប្បកម្មឡឥដ្ឋនៅកម្ពុជា


របាយការណ៍ចេញផ្សាយ
ខែវិច្ឆិកា ឆ្នាំ២០២៣

# ចំណងក្នុងឡឥដ្ឋ

## ឱកាសដើម្បីបញ្ចប់ការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារ ក្នុងសិប្បកម្មឡឥដ្ឋនៅកម្ពុជា

របាយការណ៍ចេញផ្សាយ ខែវិច្ឆិកា ឆ្នាំ២០២៣

**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ**

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស
# (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើត ឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិ នយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ ការគោរពសិទ្ធិទាំងនេះពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវ សមិទ្ធិផលល្អក្នុងអតីតកាល លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលស្ថានភាពសង្គមតាមរយៈកម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស ពីការិយាល័យកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងនៅតាមសាខាទាំង ១២ ខេត្តផ្សេងទៀត។

**កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស**

**កម្មវិធីលើកកម្ពស់ និងការទាក់ទាញមតិគាំទ្រ**

### ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ

បុគ្គលិកអង្គការលីកាដូ ធ្វើការឃ្លាំមើល និងស្រាវជ្រាវលើករណីរំលោភសិទ្ធិមនុស្ស ករណីរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែង តាមរយៈការធ្វើ អន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

### ជំនួយផ្នែកសេវាសុខភាព និងសេវាកម្មសង្គមកិច្ច

ក្រុមគ្រូពេទ្យផ្តល់សេវាសុខភាពដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារនៅជនបទ និងទីក្រុង ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងគ្រួសារ ដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសារ របស់អ្នកទាំងនោះ ហើយផ្តល់ជំនួយ សម្ភារៈ និងម្ហូបអាហារ រយៈពេលខ្លី។

### ការប្រឹក្សាផ្នែកច្បាប់ដល់ជនជាប់ឃុំ

អ្នកប្រឹក្សាផ្នែកច្បាប់ ផ្តល់ការប្រឹក្សាដល់ជនជាប់ឃុំនៅពន្ធនាគារនៅជនបទ និងទីក្រុង ដើម្បីធ្វើឲ្យប្រាកដថា ជនជាប់ឃុំទាំងនោះមានតំណាង ផ្នែកច្បាប់ នៅគ្រប់ដំណាក់កាលនៃនីតិវិធីដែលពាក់ព័ន្ធ។

### ការពិគ្រោះយោបល់ផ្នែកច្បាប់

ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការពិគ្រោះយោបល់ផ្នែកច្បាប់ ហើយចំពោះ ករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូន ដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។

### គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និង បណ្តាញនានា

ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ ដែលរងគ្រោះ ដោយផ្តល់នូវកិច្ចការពារសេវាកម្មផ្នែកច្បាប់ និងសេវាសុខភាព ព្រមទាំងជួយពង្រឹងសមត្ថភាពរបស់អ្នកទាំងនោះ ក្នុងការតស៊ូមតិ។

### ទាក់ទាញមតិគាំទ្រជាសាធារណៈ និងតាមសហគមន៍

ករណីរំលោភសិទ្ធិមនុស្ស ដែលអង្គការលីកាដូបានឃ្លាំមើល និងស្រាវជ្រាវ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិត ជារបាយការណ៍ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។


**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការ លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរសព្ទលេខ៖ (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២

អ៊ីម៉ែល៖ contact@licadho-cambodia.org
គេហទំព័រ៖ www.licadho-cambodia.org Facebook: www.facebook.com/licadho Email Digest: http://www.licadho-cambodia.org/follow.php



# មាតិកា


សេចក្តីផ្តើម ទំព័រ១

សង្ខេបអំពីការរកឃើញសំខាន់ៗ ទំព័រ២

សារតារ ទំព័រ៤

វិធីសាស្ត្រនៃការស្រាវជ្រាវ ទំព័រ៦

ទិដ្ឋភាពទូទៅអំពីដំណើរការនៃផលិតកម្មឥដ្ឋ ទំព័រ៨

ការរកឃើញ ទំព័រ១០

កម្មករសិប្បកម្មផលិតឥដ្ឋប្រឈមនឹងហានិភ័យព្រោះតែការធ្លាក់ចុះនៃវិស័យនេះ ទំព័រ១០
ការបញ្ចាំខ្លួនដោះបំណុលនៅតែបន្តរីករាលដាលដដែល ទំព័រ១៤
ពលកម្មកុមារនៅតែបន្តមាន ទំព័រ១៨
ការចុះធ្វើអធិការកិច្ចពុំមានសង្គតិភាព និងប្រសិទ្ធភាព ទំព័រ២២
ឡឥដ្ឋដុតដោយកម្ទេចសំណល់ក្រណាត់មានជាតិពុល ទំព័រ២៣
លក្ខខណ្ឌការងារ និងលទ្ធភាពទទួលបានការថែទាំងសុខភាពនៅមិនទាន់គ្រប់គ្រាន់ ទំព័រ២៨
ឥដ្ឋត្រូវបានទិញភាគច្រើនដោយគម្រោងអភិវឌ្ឍន៍បុរី ទំព័រ៣០

សេចក្តីសន្និដ្ឋាន ទំព័រ៣១

អនុសាសន៍ ទំព័រ៣២

# សេចក្តីផ្តើម

អំពើរំលោភបំពានលើសិទ្ធិមនុស្ស ដែលរួមមានទាសភាពសម័យទំនើប ការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារ នៅតែបន្តមានដដែលនៅក្នុងសិប្បកម្មផលិតឥដ្ឋនៅកម្ពុជា ។ អំពើរំលោភបំពានទាំងនេះ ត្រូវបានចងក្រងជាឯកសារជាច្រើនសន្ធឹកសន្ធាប់ដោយអង្គការមិនមែនរដ្ឋាភិបាល អ្នកសិក្សាស្រាវជ្រាវ និងអ្នកសារព័ត៌មាន ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ។ អំពើរំលោភបំពានទាំងនេះបន្តមានរហូតទល់សព្វថ្ងៃ ដោយសារមូលហេតុចម្បងគឺ អាជ្ញាធររដ្ឋតែងតែមិនទទួលស្គាល់ថាមានអំពើរំលោភបំពានទាំងនោះ ។ វិស័យឯកជន និងសហគមន៍អន្តរជាតិ ក៏មិនបានចាត់វិធានការជាក់លាក់ ដើម្បីដោះស្រាយបញ្ហាដែលកើតមានជាទូទៅទាំងនេះនៅក្នុងឧស្សាហកម្មផលិតឥដ្ឋនៅកម្ពុជានោះដែរ ។ ជាលទ្ធផល ឥដ្ឋដែលផលិតដោយពលករដែលបញ្ចាំខ្លួនដោះបំណុល និងកុមារ នៅតែបន្តប្រើប្រាស់ជាស្នូលសម្រាប់ការរីកលូតលាស់នៃសំណង់អគារ និងលំនៅដ្ឋានក្នុងប្រទេសកម្ពុជា ។

របាយការណ៍នេះ ត្រូវបានធ្វើឡើងដោយផ្អែកលើការចុះសិក្សាតាមសិប្បកម្មផលិតឥដ្ឋ និងបទសម្ភាសន៍ជាមួយកម្មករនៅក្នុងខេត្តកណ្តាល និងរាជធានីភ្នំពេញ ។ របាយការណ៍នេះ បង្ហាញនូវភស្តុតាងនៃពលកម្មដើម្បីដោះបំណុល និងពលកម្មកុមារដែលនៅតែមានជាទូទៅនៅតាមសិប្បកម្មផលិតឥដ្ឋនានា ។

**តម្រូវការឥដ្ឋបានធ្លាក់ចុះ ។**

តម្រូវការឥដ្ឋបានធ្លាក់ចុះដោយសារការថមថយនៃវិស័យសំណង់ និងអចលនទ្រព្យចាប់តាំងពីមានវិបត្តិជំងឺកូវីដ ដែលបានធ្វើឱ្យសិប្បកម្មផលិតឥដ្ឋជាច្រើនខ្វះខាតការងារ និងមួយចំនួនបានបិទអាជីវកម្ម ។ មានចម្លើយផ្សេងគ្នាជាច្រើនទទួលបានពីម្ចាស់សិប្បកម្មផលិតឥដ្ឋ ក្នុងនោះមានម្ចាស់សិប្បកម្មផលិតឥដ្ឋមួយចំនួនបានផ្ទេរពលករដោះបំណុលរបស់ខ្លួនឱ្យទៅធ្វើការងារថ្មី និងខ្លះទៀតបានលុបចោលបំណុលនិងអនុញ្ញាតឱ្យកម្មករចាកចេញពីសិប្បកម្ម ។ បើសិនជាគ្មានការធានានូវការលុបចោលបំណុល និងសេរីភាពសម្រាប់កម្មករដែលបញ្ចាំខ្លួនដោះបំណុលជាបន្ទាន់នោះទេ ទាសភាពសម័យទំនើបនៅកម្ពុជានឹងអាចរីករាលដាលដល់វិស័យឧស្សាហកម្មផ្សេងទៀត ដែលនឹងក្លាយជាបញ្ហាកាន់តែលំបាកក្នុងការលុបបំបាត់ ។

**ទាសភាពសម័យទំនើបនៅកម្ពុជានឹងអាចរីករាលដាលដល់វិស័យឧស្សាហកម្មផ្សេងទៀត ។**

នៅតាមសិប្បកម្មជាច្រើនដែលនៅមានដំណើរការ ការបញ្ចាំខ្លួនដោះបំណុលបន្តជម្រុញឱ្យកុមារជួយធ្វើការងារ ជាពិសេសកុមារមួយចំនួនដែលមានអាយុត្រឹមតែ ៩ ឆ្នាំប៉ុណ្ណោះ ។ ការអនុញ្ញាតឲ្យកុមារធ្វើការនៅតាមសិប្បកម្មផលិតឥដ្ឋ គឺជាការល្មើសនឹងច្បាប់ជាតិ និងអន្តរជាតិ ដោយសារការងារនេះ ត្រូវបានធ្វើឡើងនៅក្នុងបរិបទការធ្វើការងារដើម្បីដោះបំណុល និងជាការងារប្រកបដោយគ្រោះថ្នាក់ ។[១]

អាជ្ញាធរមួយចំនួនបានដឹង និងជួនកាលសមគំនិតក្នុងការប្រព្រឹត្តិអំពើរំលោភបំពាននៅសិប្បកម្មផលិតឥដ្ឋ ។ ទោះជាយ៉ាងនេះក្តី ការឆ្លើយតបចម្បងរបស់អាជ្ញាធរថ្នាក់ជាតិ គឺការចុះធ្វើអធិការកិច្ចការងារ បន្ទាប់មកបដិសេដថាគ្មានបញ្ហាទាំងនេះកើតឡើង ។ ហេតុដូច្នេះហើយ ម្ចាស់សិប្បកម្មផលិតឥដ្ឋបន្តទទួលបាននិទណ្ឌភាព និងមិនដែលទទួលរងការចោទប្រកាន់ចំពោះការឱ្យកម្មករបញ្ចាំខ្លួនដោះបំណុលខុសច្បាប់នោះទេ ។

[១] មាត្រា ៣(ក) និង ៣(ឃ) នៃអនុសញ្ញាស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ឆ្នាំ ១៩៩៩ (លេខ ១៨២) របស់អង្គការពលកម្មអន្តរជាតិ និងកថាខណ្ឌទី ២ នៃសេចក្តីប្រកាសលេខ ១០៦ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៤ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា ស្តីពីការហាមឃាត់ពលកម្មកុមារដែលមានទម្រង់គ្រោះថ្នាក់ ។

# សង្ខេបអំពីការរកឃើញសំខាន់ៗ

អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ បានចងក្រងព័ត៌មានអំពីសិប្បកម្មផលិតឥដ្ឋចំនួន ២១កន្លែង នៅចន្លោះខែមេសា ដល់ខែកញ្ញា ឆ្នាំ២០២៣ តាមរយៈការចុះទៅសិក្សាផ្ទាល់តាមសិប្បកម្មផលិតឥដ្ឋ ការសន្ទនាក្រៅផ្លូវការជាមួយកម្មករនិងអ្នកពាក់ព័ន្ធជាច្រើននាក់ក្នុងវិស័យនេះ និងបទសម្ភាសន៍លម្អិតជាមួយកម្មករនិងអតីតកម្មករចំនួន ១០នាក់ ។ ការជជែកសន្ទនាទាំងនោះបានបង្ហាញឱ្យឃើញថា៖

**កម្មករនៅតាមសិប្បកម្មផលិតឥដ្ឋកំពុងប្រឈមនឹងហានិភ័យ ដោយសារតែការធ្លាក់ចុះនៃឧស្សាហកម្ម ។** សិប្បកម្មចំនួនប្រាំបីកន្លែងដែលអង្គការលីកាដូបានចុះសិក្សាបានកាត់បន្ថយ ឬផ្អាកដំណើរការផលិតឥដ្ឋ ហើយសិប្បកម្មចំនួនប្រាំទៀតបានបិទអាជីវកម្មទាំងស្រុង ។ ម្ចាស់សិប្បកម្មភាគច្រើនអនុញ្ញាតឱ្យកម្មករជាប់បំណុលរបស់ខ្លួនទៅរស់នៅ ឬធ្វើការនៅកន្លែងផ្សេងបណ្តោះអាសន្ន ខណៈដែលម្ចាស់សិប្បកម្មខ្លះទៀតឱ្យកម្មកររង់ចាំក្នុងសិប្បកម្មរហូតដល់មានដំណើរការផលិតកម្មឡើងវិញ ដោយមិនផ្តល់ប្រាក់ឈ្នួល ។ គួរឱ្យព្រួយបារម្ភនោះ មានម្ចាស់សិប្បកម្មផលិតឥដ្ឋចំនួនបីកន្លែង បានផ្ទេរពលករជាប់បំណុលមួយចំនួនទៅកន្លែងការងារថ្មី ខណៈដែលម្ចាស់សិប្បកម្មចំនួនបីទៀត បានលុបចោលបំណុលរបស់កម្មករទាំងអស់ ឬមួយចំនួនអនុញ្ញាតឱ្យពួកគេរួចផុតពីការបញ្ចាំខ្លួន ដោះបំណុល ។

**ការបញ្ចាំខ្លួនដោះបំណុលនៅតែកើតមានជាទូទៅ ។** កម្មករសិប្បកម្មផលិតឥដ្ឋបច្ចុប្បន្នទាំងអស់ដែលបានចូលរួមបទសម្ភាសជាមួយអង្គការលីកាដូ សុទ្ធតែជាប់ជំពាក់បំណុលម្ចាស់សិប្បកម្ម ។ កម្មករមួយចំនួនមិនត្រូវបានអនុញ្ញាតឱ្យស្នាក់នៅ ឬធ្វើការនៅខាងក្រៅ រហូតដល់អ្នកទាំងនោះដោះបំណុលជាមួយម្ចាស់សិប្បកម្មរួចរាល់ ។ ការផ្តល់កម្ចីដោយមិនគិតការប្រាក់ទាក់ទាញឱ្យកម្មករធ្វើការនៅសិប្បកម្មផលិតឥដ្ឋ ប៉ុន្តែពួកគេទទួលបានប្រាក់ឈ្នួលទាបខ្លាំងស្ទើរតែមិនអាចដោះបំណុលរបស់ពួកគេបាន ។ ម្ចាស់សិប្បកម្មផលិតឥដ្ឋខ្លះដកទុកឯកសារបញ្ជាក់អត្តសញ្ញាណរបស់កម្មករ ឬតម្រូវឱ្យសមាជិកម្នាក់នៃគ្រួសារជំពាក់បំណុលនីមួយៗបន្តនៅសិប្បកម្មផលិតឥដ្ឋជានិច្ច ដើម្បីធានាថាសមាជិកផ្សេងទៀតនឹងត្រឡប់មកសិប្បកម្មវិញ ។ កម្មករខ្លះក៏បានរាយការណ៍ថាកិច្ចសន្យាផ្តល់កម្ចីត្រូវបានចុះហត្ថលេខានៅមុខអាជ្ញាធរ ដែលអាជ្ញាធរទាំងនោះជួនកាលជួយតាមរកកម្មករដែលព្យាយាមរត់គេចពីសិប្បកម្មផលិតឥដ្ឋ ។

**ពលកម្មកុមារនៅតែបន្តមាន ។** កុមារអាយុចាប់ពី ៩ ដល់ ១៧ឆ្នាំ នៅតែបន្តធ្វើការក្រោមទម្រង់ជាពលកម្មកុមារនៅតាមសិប្បកម្មផលិតឥដ្ឋនៅកម្ពុជា ។ អង្គការលីកាដូ បានសង្កេតឃើញកុមារធ្វើការនៅសិប្បកម្មផលិតឥដ្ឋចំនួនពីរកន្លែង និងទទួលបានការរាយការណ៍អំពីពលកម្មកុមារនៅសិប្បកម្មផលិតឥដ្ឋចំនួនបួនកន្លែងផ្សេងទៀត ។ ការបញ្ចាំខ្លួនដោះបំណុល និងការគិតប្រាក់ឈ្នួលទាបតាមចំនួនដុំឥដ្ឋ គឺជាឫសគល់នៃពលកម្មកុមារ ដោយសារកម្មករគិតថាពួកគេគ្មានជម្រើស ដូច្នេះហើយត្រូវតែបញ្ជូនសមាជិកគ្រួសារផ្សេងទៀតឱ្យមកជួយធ្វើការ ។ អង្គការលីកាដូ បានឃើញផ្ទាល់ ឬទទួលបានការរាយការណ៍អំពីករណីកុមារលីសែងដីឥដ្ឋដាក់ចូលក្នុងម៉ាស៊ីនផលិតឥដ្ឋដែលប្រកបដោយគ្រោះថ្នាក់ និងករណីកុមារលើកជញ្ជូនឥដ្ឋដាក់លើ និងដាក់ចុះពីរទេះ និងរថយន្តដឹកជញ្ជូន ។





**ការចុះធ្វើអធិការកិច្ចគ្មានសង្គតិភាព និងគ្មានប្រសិទ្ធភាព ។** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានតួនាទីធ្វើអធិការកិច្ចលើសិប្បកម្មផលិតឥដ្ឋ ។ កម្មករជាច្រើននាក់មិនធ្លាប់ឃើញមានការចុះពិនិត្យទាល់តែសោះ ឬក្នុងអំឡុងពេល ៥ឆ្នាំកន្លងមកនេះ ។ កម្មករផ្សេងទៀតបានប្រាប់ឱ្យដឹងថាអាជ្ញាធរធ្លាប់ចុះពិនិត្យលើសិប្បកម្មផលិតឥដ្ឋ និងជូនកាលប្រកាសហាមកុមារធ្វើការ ឬទៅក្បែរឡឥដ្ឋ ឬម៉ាស៊ីនផលិតឥដ្ឋ ។ អន្តរាគមន៍បែបនេះមិនបានជួយកាត់បន្ថយពលកម្មកុមារនោះទេ ដោយសារវាមិនបានដោះស្រាយឫសគល់នៃការបញ្ចាំខ្លួនដោះបំណុល ឬប្រាក់ឈ្នួលទាបនិងមិនមានការដាក់ទណ្ឌកម្មលើម្ចាស់សិប្បកម្មផលិតឥដ្ឋចំពោះអំពើរំលោភបំពាន។

---

**ឥដ្ឋនៅក្នុងឡត្រូវបានដុតដោយសំណល់កំទេចក្រណាត់របស់ក្រុមហ៊ុនសំលៀកបំពាក់ម៉ាក់ល្បីៗអន្តរជាតិមួយចំនួន ។** អង្គការលីកាដូ បានរកឃើញកំទេចក្រណាត់នៅសិប្បកម្មផលិតឥដ្ឋចំនួនប្រាំពីរកន្លែង ដែលរួមមានសំណល់របស់ក្រុមហ៊ុនសំលៀកបំពាក់ម៉ាកអន្តរជាតិដូចជា អេឌីដាស រីបុក អាន់ដើអាមមើ លូលូឡេម៉ិន ហ្គាប អូលណាវី ព្រីម៉ាក វ៉លម៉ាត និងម៉ាកល្បីៗផ្សេងទៀត ។ សំណល់ឧស្សាហកម្មកាត់ដេរត្រូវបានគេប្រើដើម្បីដុតបញ្ឆេះឡឥដ្ឋ បើទោះជាវាមានផលប៉ះពាល់ដល់សុខភាព និងបរិស្ថានយ៉ាងណាក្តី ។ កម្មករបានរាយការណ៍អំពីបញ្ហាផ្លូវដង្ហើម ការឈឺក្បាល និងគ្រោះថ្នាក់ផ្សេងៗដែលបង្កដោយការដុតសំណល់កម្ទេចក្រណាត់ ។

---

**លក្ខខណ្ឌការងារ និងលទ្ធភាពទទួលបានសេវាថែទាំសុខភាពនៅមិនទាន់មានគ្រប់គ្រាន់ ។** កម្មករមិនទទួលបានកិច្ចសន្យាការងារ អត្ថប្រយោជន៍ផ្សេងៗកំណត់ដោយច្បាប់ដូចជាការឈប់សម្រាកដោយមានប្រាក់ឈ្នួល ឬសម្ភារៈការពារសុវត្ថិភាព ។ កម្មករជាច្រើននាក់បានរាយការណ៍ថាខ្លួនគ្មានសមត្ថភាពបង់ថ្លៃសេវាព្យាបាល ។ ម្ចាស់សិប្បកម្មភាគច្រើនបានឈប់ផ្តល់កម្ចីបន្ថែមដល់កម្មករសម្រាប់ចំណាយលើសេវាថែទាំសុខភាពក្រោយពីតម្រូវការឥដ្ឋមានការថយចុះ។

---

**ឥដ្ឋត្រូវបានទិញក្នុងចំនួនច្រើនលើសលុបដោយគម្រោងអភិវឌ្ឍន៍បុរី ។** កម្មករ ម្ចាស់សិប្បកម្មផលិតឥដ្ឋ និងអ្នកបើករថយន្តដឹកជញ្ជូន បានរាយការណ៍ថាឥដ្ឋបច្ចុប្បន្ននេះត្រូវបានលក់ទៅឱ្យគម្រោងសាងសង់បុរី នៅក្នុងរាជធានីភ្នំពេញ ។ ទោះជាយ៉ាងនេះក្តី ភាគីដែលទិញឥដ្ឋនៅកម្ពុជាប្រឈមនឹងអំពើរំលោភបំពានលើសិទ្ធិមនុស្សក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់ខ្លួន ដោយសារពលកម្មដើម្បីដោះបំណុល និងពលកម្មកុមារមានការរីករាលដាលយ៉ាងខ្លាំងនៅក្នុងឧស្សាហកម្មផលិតឥដ្ឋ ។

---

# សាវតារ

អំពើរំលោភបំពានលើសិទ្ធិមនុស្ស មានរីករាលដាលនៅសិប្បកម្មផលិតឥដ្ឋជាច្រើនទសវត្សរ៍មកហើយ ។ អង្គការលីកាដូ បានកត់ត្រាទុកនូវករណីកុមាររងរបួសខណៈកំពុងធ្វើការនៅសិប្បកម្មផលិតឥដ្ឋចាប់តាំងពីឆ្នាំ ១៩៩៩ មកម៉្លេះ ហើយអំឡុងទសវត្សរ៍ឆ្នាំ ២០០០ បានចេញផ្សាយភស្តុតាងដែលបង្ហាញពីចំនួនកុមាររាប់រយនាក់ ដែលកំពុងធ្វើការក្នុងវិស័យសិប្បកម្មនេះ ។[២] របាយការណ៍ឆ្នាំ២០១៦ របស់អង្គការលីកាដូអំពីសិប្បកម្មផលិតឥដ្ឋបានរកឃើញថាពលកម្មកុមារ និងការបញ្ចាំខ្លួនដោះបំណុលនៅតែបន្តមានជាបញ្ហា ។[៣]

ក្រោយមានការចុះផ្សាយដោយសារព័ត៌មានក្នុងស្រុក និងក្រៅស្រុកជាច្រើនបន្តបន្ទាប់ពីអំពើរំលោភបំពានទាំងនេះ នៅខែឧសភា ឆ្នាំ២០១៨ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាន "ជួយសង្គ្រោះ" កុមារចំនួន ២៤០ នាក់ពីពលកម្មធ្ងន់ធ្ងរនៅសិប្បកម្មផលិតឥដ្ឋ ហើយមន្ទីរការងារខេត្តសៀមរាបបានបិទរោងសិប្បកម្មផលិតឥដ្ឋចំនួនបីកន្លែង និងផ្អាកដំណើរការសិប្បកម្មចំនួនប្រាំកន្លែងផ្សេងទៀត ។[៤] ចំណាត់ការនេះនៅមិនទាន់គ្រប់គ្រាន់ដើម្បីដោះស្រាយបញ្ហានៃអំពើរំលោភបំពាន ដែលកើតមានសុសសាយនៅតាមសិប្បកម្មផលិតឥដ្ឋជាច្រើនរាប់រយនៅទូទាំងប្រទេសនោះឡើយ ។

នៅខែតុលា ឆ្នាំ២០១៨ អ្នកសិក្សាស្រាវជ្រាវមកពីសាកលវិទ្យាល័យឡុងដុង រ៉ូយ៉ាល់ ហូឡូវេ បានចេញផ្សាយរបាយការណ៍ស្រាវជ្រាវស្តីពី "ដុំឥដ្ឋលោហិតកម្ពុជា" ដែលបានរកឃើញការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារ ក៏ដូចជាការប្រើកម្មេចសំណល់គ្រោះថ្នាក់ និងទំនាក់ទំនងរវាងឧស្សាហកម្មនេះ និងការប្រែប្រួលអាកាសធាតុផងដែរ ។[៥] ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានប្រកាសថានឹងធ្វើការស៊ើបអង្កេតលើការចោទប្រកាន់ទាំងនេះ ។[៦]

នៅខែមីនា ឆ្នាំ២០១៩ ពលរដ្ឋកម្ពុជាបានសម្តែងភាពខឹងសម្បារតាមបណ្តាញសង្គមបន្ទាប់ពីក្មេងស្រីអាយុ ១០ឆ្នាំម្នាក់បានជួបគ្រោះថ្នាក់ដាច់ដៃម្ខាងដោយសារគៀបចូលម៉ាស៊ីនផលិតឥដ្ឋ ។[៧] ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានធ្វើការផាកពិន័យសិប្បកម្មមួយនោះ និងប្រកាសយុទ្ធនាការបញ្ចប់ពលកម្មកុមារនៅសិប្បកម្មផលិតឥដ្ឋឱ្យបានត្រឹមឆ្នាំ២០២០[៨] ដោយបានចេញសេចក្តីណែនាំឱ្យមន្ទីរការងាររាជធានីខេត្តទាំងអស់ ធ្វើការអប់រំម្ចាស់សិប្បកម្មផលិតឥដ្ឋអំពីការ



---

[២] ឯកសារសង្ខេបអំពីអំពើរំលោភបំពាន/អំពើហិង្សាលើកុមារ និងការកេងប្រវ័ញ្ចនៅកម្ពុជា របស់អង្គការលីកាដូ ទំព័រទី៣ ឆ្នាំ២០០០ អាចរកបាននៅ https://www.licadho-cambodia.org/reports/files/22BRIEFING%20ON%20CHILD%20ABUSE.pdf។ ពលករកុមារនៅសិប្បកម្មផលិតឥដ្ឋ៖ មូលហេតុ និងផលវិបាក របស់អង្គការលីកាដូ និងអង្គការទស្សនៈពិភពលោកកម្ពុជា ឆ្នាំ២០០៧ អាចរកបាននៅ https://www.licadho-cambodia.org/reports/files/120LICADHOWVCChildLaborReport.pdf ។ ការងារកុមារនៅកម្ពុជា៖បញ្ហាប្រឈមចំពោះកំណើន និងការកាត់បន្ថយភាពក្រីក្រ របស់អង្គការពលកម្មអន្តរជាតិ អង្គការយូនីសេហ្វ និងធនាគារពិភពលោក ទំព័រទី២៩ ឆ្នាំ២០០៦ អាចរកបាននៅ https://archive.crin.org/sites/default/files/images/docs/WB_Child_labour.pdf

[៣] ការអភិវឌ្ឍលើទាសភាព៖ ការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារនៅក្នុងសិប្បកម្មផលិតឥដ្ឋនៅកម្ពុជា របស់អង្គការលីកាដូ ឆ្នាំ២០១៦ អាចរកបាននៅ https://www.licadho-cambodia.org/reports.php?perm=221

[៤] ម៉ិច ដារ៉ា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានចុះស៊ើបអង្កេត និងបិទសិប្បកម្មជាច្រើនដោយសារមានពលកម្មកុមារ ភ្នំពេញប៉ុស្ដិ៍ ចុះផ្សាយថ្ងៃ២៣ ខែឧសភា ឆ្នាំ២០១៨ អាចរកបាននៅ https://www.phnompenhpost.com/national/ncct-investigating-and-closing-down-factories-over-child-labour

[៥] Katherine Brickell, Laurie Parsons, Nithya Natarajan និងសុភ័ក្រ ច័ន្ទ របាយការណ៍ស្ដីពីដុំឥដ្ឋលោហិត៖ រឿងរ៉ាវដែលគេមិនធ្លាប់ប្រាប់អំពីទាសភាពសម័យទំនើប និងការប្រែប្រួលអាកាសធាតុ របស់សាកលវិទ្យាល័យឡុងដុង រ៉ូយ៉ាល់ ហូឡូវេ ឆ្នាំ២០១៨ អាចរកបាននៅ https://static1.squarespace.com/static/596df9f8d1758e3b451e0fb2/t/5bc4d7cdc83025e41e7b10a0/1539627177544/Blood+bricks+high+res+v2.pdf%20; និងសូមមើលផ្នែក "របាយការណ៍បោះពុម្ពនានា" របស់គម្រោងស្រាវជ្រាវ Blood Bricks អាចរកបាននៅ https://www.projectbloodbricks.org/publications

[៦] ម៉ិច ដារ៉ា "ក្រសួងនឹងស៊ើបអង្កេតអំពីពលកម្មកុមារ" ភ្នំពេញប៉ុស្ដិ៍ ចុះផ្សាយថ្ងៃ១៩ ខែតុលា ឆ្នាំ២០១៨ អាចរកបាននៅ https://www.phnompenhpost.com/national/ministry-probe-child-labour

[៧] សូមមើលសេចក្តីថ្លែងការណ៍ "នៅថ្ងៃទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ លីកាដូស្នើសុំឱ្យអាជ្ញាធរអនុវត្តច្បាប់ស្តីពីពលកម្មកុមារឱ្យមានប្រសិទ្ធភាព" របស់អង្គការលីកាដូ ឆ្នាំ២០១៩ អាចរកបាននៅ https://www.licadho-cambodia.org/pressrelease.php?perm=440

[៨] Leonie Kijewski "កម្ពុជាបើកយុទ្ធនាការបញ្ចប់ពលកម្មកុមារនៅតាមសិប្បកម្មផលិតឥដ្ឋ" សម្លេងសហរដ្ឋអាមេរិក (វីអូអេ) ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៩ អាចរកបាននៅ https://www.voanews.com/a/east-asia-pacific_cambodia-launches-campaign-end-child-labor-brick-industry/6175344.html



ហាមឃាត់ការបញ្ចាំខ្លួនដោះបំណុល ពលកម្មកុមារ និងហាមឃាត់កុមារចូលក្នុងបរិវេណខ្សែសង្វាក់ផលិតកម្ម ។ ក្នុងសេចក្តីណែនាំ មានការព្រមានចាត់វិធានការផ្នែកព្រហ្មទណ្ឌ ឬបិទអាជីវកម្មរបស់សិប្បកម្មណាដែលមិនបានអនុវត្តតាម ។[៩]

ការសិក្សាស្ទង់មតិឯករាជ្យថ្នាក់ជាតិមួយអំពីឧស្សាហកម្មផលិតឥដ្ឋ ដែលធ្វើឡើងក្នុងឆ្នាំ២០១៩ បានរកឃើញថាមានមនុស្សជាង ១០ ០០០ នាក់ ក្នុងនោះមានកុមារជិត ៤ ០០០នាក់ កំពុងរស់នៅក្នុងសិប្បកម្មផលិតឥដ្ឋដែលដំណើរការចំនួន ៤៦៤ ទីតាំង នៅទូទាំងប្រទេស ។ ការសិក្សានេះបានរកឃើញថាកុមារអាយុក្រោម ១៨ ឆ្នាំចំនួន ៦៣៨ នាក់ កំពុងធ្វើការនៅសិប្បកម្មផលិតឥដ្ឋ យ៉ាងណាក្តីចំនួនជាក់ស្តែងអាចមានច្រើនជាងនេះដោយសារប្រភេទនៃការងារនេះមានលក្ខណៈបណ្តោះអាសន្ន និងមិនទៀងទាត់ ។[១០]

ទោះជាយ៉ាងនេះក្តី នៅខែមករា ឆ្នាំ២០២០ អ្នកនាំពាក្យរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រាប់ថាមន្ត្រីអធិការកិច្ចការងារបានចុះត្រួតពិនិត្យសិប្បកម្មផលិតឥដ្ឋនៅគ្រប់ទីតាំងក្នុងប្រទេសកម្ពុជា និងបានរកឃើញថា "គ្មានពលកម្មកុមារនៅតាមសិប្បកម្មផលិតឥដ្ឋឡើយ" ។[១១] ដូចគ្នានេះដែរ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានរាយការណ៍ជូនក្រសួងការងារសហរដ្ឋអាមេរិក នៅខែវិច្ឆិកា ឆ្នាំ២០២០ ថាក្រសួងមិនបានកំណត់ឃើញនូវ "ករណីពលកម្មកុមារ ឬការបញ្ចាំខ្លួនដោះបំណុល ឬពលកម្មដោយបង្ខំ" ឡើយ ក្រោយពីបានធ្វើជំរឿនជាមួយសិប្បកម្មផលិតឥដ្ឋចំនួន ៤៨៦ រួចមក ។[១២] រាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំនេះជាថ្មីម្តងទៀតបានរាយការណ៍ថាក្នុងគ្រប់វិស័យ និងឧស្សាហកម្មទាំងអស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះធ្វើអធិការកិច្ចចំនួន ៧៥២ លើកគិតចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ និងជាលទ្ធផលពុំមានករណីពលកម្មកុមារ និងទាសភាពបំណុលកើតមានឡើយ ។[១៣]

អ្នកសារព័ត៌មាន បានចងក្រងជាឯកសារអំពីការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារនៅតាមសិប្បកម្មផលិតឥដ្ឋក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១ ។[១៤] នៅខែកក្កដា ឆ្នាំ២០២២ ក្រសួងការងារសហរដ្ឋអាមេរិកបានបញ្ចូលបន្ថែមដុំឥដ្ឋកម្ពុជាទៅក្នុងបញ្ជីផលិតផល ដែលផលិតដោយមានពលកម្មដោយបង្ខំ ឬពលកម្មកុមារ ។[១៥] ដូចមានបកស្រាយក្នុងរបាយការណ៍នេះ អង្គការលីកាដូមិនបានរកឃើញនូវភាពប្រសើរឡើងជាងមុនដែលមានលក្ខណៈជាប្រព័ន្ធចាប់តាំងពីរបាយការណ៍មុនរបស់ខ្លួននៅឆ្នាំ២០១៦ មកនោះទេ ។

---

[៩] សេចក្តីណែនាំលេខ០៥៦/១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការហាមកុមារចូលទៅក្នុងបរិវេណខ្សែសង្វាក់ផលិតកម្មឥដ្ឋ នៃសិប្បកម្មផលិតឥដ្ឋរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

[១០] "ការស្ទង់មតិអំពីឧស្សាហកម្មឥដ្ឋកម្ពុជា៖ ចំនួនប្រជាជន ភូមិសាស្ត្រ និងការអនុវត្ត" គម្រោងស្រាវជ្រាវ Blood Bricks ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២០ https://www.projectbloodbricks.org/blog/2020/5/26/tdc34d18vw1fzarb3m80fcwu20r0oi

[១១] Leonie Kijewski "របាយការណ៍បានរកឃើញថាកុមាររយនាក់នៅកម្ពុជាធ្វើការនៅសិប្បកម្មផលិតឥដ្ឋ", សម្លេងសហរដ្ឋអាមេរិក (វីអូអេ) ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ អាចរកបាននៅ https://www.voanews.com/a/east-asia-pacific_100s-children-cambodia-work-brick-factories-report-finds/6184260.html

[១២] "កម្មវត្ថុ៖ ការបកស្រាយបំភ្លឺអំពីរបាយការណ៍ពលកម្មកុមារជាសកលក្នុងកម្ពុជារបស់សហរដ្ឋអាមេរិក" លិខិតរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទៅកាន់ក្រសួងការងារសហរដ្ឋអាមេរិក ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០ អាចរកបាននៅ https://www.regulations.gov/comment/DOL-2020-0008-0002

[១៣] កំណត់សម្គាល់ដោយសហរដ្ឋអាមេរិកទៅលើរបាយការណ៍របស់អ្នករាយការណ៍ពិសេសអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា Vitit Muntarbhorn A/HRC/54/75/Add.1 កថាខណ្ឌទី៣៧ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣ អាចរកបាននៅ https://undocs.org/en/A/HRC/54/75/Add.1

[១៤] Matt Blomberg "របាយការណ៍លាតត្រដាងបង្ហាញនូវពលកម្មកុមារនៅតាមសិប្បកម្មឡឥដ្ឋរបស់កម្ពុជា ទោះជាមានការបង្ក្រាបយ៉ាងណាក្តី" មូលនិធិ Thomson Reuters Foundation ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ អាចរកបាននៅ https://www.reuters.com/article/us-cambodia-construction-child-labour-idUSKBN20702Y។ យួន ណារីម "ទាសភាពបំណុល និងពលកម្មកុមារនៅតែមានជាទូទៅដដែលនៅតាមសិប្បកម្មឡឥដ្ឋ" ខេមបូចា ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១ អាចរកបាននៅ https://cambojanews.com/debt-bondage-and-child-labor-remains-stubbornly-prevalent-at-brick-kilns/

[១៥] "បញ្ជីផលិតផលដែលផលិតដោយពលកម្មដោយបង្ខំ ឬពលកម្មកុមារ" ក្រសួងការងារសហរដ្ឋអាមេរិកអាចរកបាននៅ https://www.dol.gov/agencies/ilab/reports/child-labor/list-of-products។ "សេចក្តីជូនដំណឹងស្តីពីការសម្រេចចុងក្រោយឱ្យដាក់បញ្ចូលឥដ្ឋកម្ពុជាក្នុងបញ្ជីផលិតផលដែលតម្រូវឱ្យមានវិញ្ញាបនបត្រអ្នកម៉ៅការសហព័ន្ធដែលបញ្ជាក់អំពីពលកម្មដោយបង្ខំ ឬពលកម្មកុមារអនុលោមតាមសេចក្តីណែនាំលេខ ១៣១២៦" ក្រសួងការងារសហរដ្ឋអាមេរិក ខែកក្កដា ឆ្នាំ២០២២ អាចរកបាននៅ https://www.federalregister.gov/documents/2022/07/13/2022-14799/notice-of-final-determination-to-add-cambodia-bricks-to-the-list-of-products-requiring-federal

# វិធីសាស្ត្រនៃការស្រាវជ្រាវ

**២១**

**សិប្បកម្មផលិតឥដ្ឋ នៅក្នុងខេត្តកណ្ដាល និងរាជធានីភ្នំពេញ ។**

**១០នាក់**

**នៃកម្មករ និងអតីតកម្មករបានចូលរួមសម្ភាសន៍ស៊ីជម្រៅដែលមានលក្ខណៈពាក់កណ្ដាលរចនាសម្ព័ន្ធ (semi-structured) ។**

**១៨ឆ្នាំ**

**រយៈពេលជាមធ្យម ដែលកម្មករបានចូលរួមបទសម្ភាសន៍ បានរស់នៅ និងធ្វើការនៅសិប្បកម្មផលិតឥដ្ឋ ។**

នៅចន្លោះខែមេសា ដល់ខែកញ្ញា ឆ្នាំ២០២៣ អង្គការលីកាដូ បានប្រមូលព័ត៌មានពីសិប្បកម្មផលិតឥដ្ឋចំនួន២១ ទីតាំងនៅក្នុងខណ្ឌស្រុកចំនួនបួននៃខេត្តកណ្ដាល និងរាជធានីភ្នំពេញ ។ អង្គការលីកាដូ បានចុះទៅសិក្សាសិប្បកម្មផលិតឥដ្ឋចំនួន២០ ទីតាំង និងទទួលបានព័ត៌មានអំពីសិប្បកម្មមួយកន្លែងទៀតតាមរយៈកិច្ចសម្ភាសន៍ផ្លូវការដែលធ្វើឡើងនៅក្រៅបរិវេណសិប្បកម្មជាមួយកម្មករម្នាក់ ។

នៅក្នុងការចុះសិក្សាទាំងនេះ បុគ្គលិកអង្គការលីកាដូបានជជែកសន្ទនាក្រៅផ្លូវការយ៉ាងច្រើនជាមួយកម្មករបច្ចុប្បន្ន និងអតីតកម្មករ ម្ចាស់សិប្បកម្មផលិតឥដ្ឋ និងអ្នកបើកបរយន្តដឹកជញ្ជូន ។ លើសពីនេះ កម្មករ និងអតីតកម្មករចំនួន ១០ នាក់បានចូលរួមសម្ភាសន៍ស៊ីជម្រៅដែលមានលក្ខណៈពាក់កណ្ដាលរចនាសម្ព័ន្ធ (semi-structured) ។ កម្មករទាំងនេះ រួមមានស្ត្រីប្រាំពីរនាក់ និងបុរសបីនាក់ ដែលកំពុងរស់នៅក្នុងសិប្បកម្មផលិតឥដ្ឋ និងបានធ្វើចំណាកស្រុកមកពីខេត្តកំពង់ចាម កំពង់ធំ កំពត ព្រៃវែង ពោធិ៍សាត់ ស្វាយរៀង និងត្បូងឃ្មុំ ព្រមទាំងវៀតណាមខាងត្បូងផងដែរ ។

ស្រុកមួយចំនួននៅក្បែររាជធានីភ្នំពេញ ដែលមានសិប្បកម្មផលិតឥដ្ឋច្រើន ត្រូវបានដាក់បញ្ចូលក្នុងការសិក្សានេះ ។ សិប្បកម្មត្រូវបានជ្រើសរើសដោយមិនមានការកំណត់ទុកជាមុន និងផ្អែកលើភាពងាយស្រួលនៃការធ្វើដំណើរចូលទៅសិក្សា ។ បទសម្ភាសន៍ជាមួយកម្មករស្ទើរទាំងអស់ធ្វើឡើងក្នុងសិប្បកម្មផលិតឥដ្ឋនៅទីតាំង ដែលអ្នកផ្ដល់កិច្ចសម្ភាសន៍ជ្រើសរើស ។ ដូចនេះ បទសម្ភាសន៍ភាគច្រើនធ្វើឡើងដោយគ្មានជាលក្ខណៈឯកជន និងជាទូទៅមានការចូលរួមពីសមាជិកគ្រួសារ និងកម្មករផ្សេងទៀត ។ ក៏ប៉ុន្តែ គ្មានបទសម្ភាសន៍ណាមួយដែលធ្វើឡើងដោយមានវត្តមានម្ចាស់សិប្បកម្មផលិតឥដ្ឋឡើយ ។ ខណៈដែលបទសម្ភាសន៍គួរតែមានជាលក្ខណៈឯកជនវាជាការពិបាកក្នុងការរកទីតាំងមួយស្ងាត់ក្នុងឬក្បែរបរិវេណសិប្បកម្មផលិតឥដ្ឋ។

កម្មករ និងអតីតកម្មករត្រូវបានអញ្ជើញចូលរួមក្នុងកិច្ចសម្ភាសន៍ ដោយផ្អែកលើពេលវេលាទំនេរ និងការស្ម័គ្រចិត្តរបស់ពួកគេ ។ អង្គការលីកាដូ បានពន្យល់ប្រាប់អំពីគោលបំណងនៃការស្រាវជ្រាវ និងការប្រើប្រាស់ព័ត៌មានដែលនឹងទទួលបានពីអ្នកចូលរួម ដើម្បីឱ្យពួកគេបានយល់ច្បាស់មុនសុំការយល់ព្រមពីពួកគេ ។ គ្រប់កម្មករទាំងអស់ ចូលរួមក្រោមលក្ខខណ្ឌជាអនាមិក ។ អង្គការលីកាដូបានសួរនាំអំពីសិប្បកម្មផលិតឥដ្ឋ ប្រវត្តិរបស់កម្មករ លក្ខខណ្ឌការងារ និងស្ថានភាពរស់នៅរបស់ពួកគេ បំណុល ទំនាក់ទំនងជាមួយអាជ្ញាធរ ប្រភេទការងារដែលកុមារធ្វើ និងអារម្មណ៍ចំពោះកត្តាការងារ និងជីវភាពរបស់កម្មករ ។ កម្មករជាច្រើននាក់ក៏បានចែករំលែកអំពីស្ថានភាពរបស់សមាជិកគ្រួសារ ឬកម្មករដទៃដែលរស់នៅក្នុងសិប្បកម្មផលិតឥដ្ឋផ្សេងទៀតផងដែរ ។

កម្មករដែលបានចូលរួមបទសម្ភាសន៍ បានរស់នៅ និងធ្វើការនៅសិប្បកម្មផលិតឥដ្ឋ អស់រយៈពេល ១៨ឆ្នាំ ជាមធ្យម ដោយមានចាប់ពី ៦ឆ្នាំ ដល់ ៣០ឆ្នាំ សម្រាប់កម្មករម្នាក់ៗ ។ ដូច្នេះរបាយការណ៍នេះមិនពិភាក្សាអំពីកត្តាដែលជម្រុញឱ្យកម្មករធ្លាក់ចូលក្នុងវិស័យសិប្បកម្មផលិតឥដ្ឋដូចជាកត្តាបំណុលមីក្រូហិរញ្ញវត្ថុ និងការប្រែប្រួលអាកាសធាតុនោះទេ ផ្ទុយទៅវិញការសិក្សាផ្ដោតសំខាន់ជុំវិញបទពិសោធន៍បច្ចុប្បន្នរបស់កម្មករសិប្បកម្មផលិតឥដ្ឋ ។



កុមារកំពុងលេងដុំឥដ្ឋ

# ទិដ្ឋភាពទូទៅអំពីដំណើរការនៃផលិតកម្មឥដ្ឋ

***អង្គការលីកាដូ បានសង្កេតឃើញ ឬលឺការរាយការណ៍អំពីកុមារធ្វើការងារក្នុងសិប្បកម្មក្នុងឆ្នាំនេះ ។ (សរសេរជាឃ្លាពណ៌ខៀវ)***

ការផលិតឥដ្ឋចាប់ផ្តើមដោយការជីកយកដីឥដ្ឋពីដីនៅក្បែរសិប្បកម្ម ឬនៅទីតាំងផ្សេងៗក្នុងប្រទេស ។ ដីឥដ្ឋត្រូវដាក់ចូលក្នុងម៉ាស៊ីនផលិតឥដ្ឋដែលមានកម្រិតនៃការបញ្ជាដោយស្វ័យប្រវត្តិផ្សេងៗគ្នា ។

**ដីឥដ្ឋត្រូវបានកាត់ និងដាក់ចូលម៉ាស៊ីនចាក់ពុម្ពឥដ្ឋ ដោយប្រើដៃ ។** ម៉ាស៊ីនភាគច្រើនមិនមានរបាំងព័ទ្ធការពារការកៀបដៃ ឬជើងកម្មករចូលក្នុងម៉ាស៊ីន ដែលជាទូទៅបានបង្កឱ្យមានគ្រោះថ្នាក់បាត់បង់អវយវៈ ។[១៦] ម៉ាស៊ីនទំនើបថ្មីៗដែលមានកម្រិតបញ្ជាស្វ័យប្រវត្តិខ្ពស់ ត្រូវដាក់ដីឥដ្ឋចូលដោយម៉ាស៊ីនជីកដី ។ ខណៈដែលសិប្បកម្មមួយចំនួនបានផ្លាស់ប្តូរម៉ាស៊ីនឧបករណ៍របស់ខ្លួនឱ្យកាន់តែទំនើបឡើង សិប្បកម្មមួយចំនួនទៀតនៅតែបន្តប្រើម៉ាស៊ីនបញ្ជាដោយដៃដែលប្រកបដោយគ្រោះថ្នាក់ ។

ម៉ាស៊ីនចាក់ពុម្ពឥដ្ឋចេញជាដុំរត់តាមខ្សែបញ្ជូន ។ **ឥដ្ឋនៅទន់ត្រូវកាត់តម្រឹមទំហំ ដោយដៃកម្មករដោយប្រើឧបករណ៍សរសៃលួស** ឬក៏កាត់ដោយស្វ័យប្រវត្តិ ប្រសិនបើម៉ាស៊ីនមានមុខងារនេះ ។ កម្មករពីរ ឬបីនាក់ ជាធម្មតា**ជញ្ជូនឥដ្ឋពីម៉ាស៊ីន ដោយប្រើដៃជញ្ជូនដាក់លើរទេះ** ។ ម៉ាស៊ីនទំនើបៗផលិតដុំឥដ្ឋបានរហ័សជាង និងត្រូវការមនុស្សច្រើនជាងដើម្បី**ជញ្ជូនឥដ្ឋពីខ្សែបញ្ជូនរបស់ម៉ាស៊ីនដាក់លើរទេះ** ។

បន្ទាប់មកឥដ្ឋនៅលើរទេះត្រូវបា**នរុញយកទៅតម្រៀបជាជួរដើម្បីហាលឱ្យស្ងួត** ។ ឥដ្ឋជួនកាល**គ្របដោយផ្ទាំងសំពត់ការពារទឹក**នៅពេលមានភ្លៀង បើសិនជាគ្មានដំបូលបាំង ។ ក្រោយពេលស្ងួត ឥដ្ឋត្រូវបានជញ្ជូនដាក់លើរទេះវិញ និងរុញទៅឡឥដ្ឋដែលនៅក្បែរ ។ ការរុញរទេះ ដែលផ្ទុកពេញទៅដោយដុំឥដ្ឋ គឺត្រូវការដៃទាំងពីរ និងកំលាំងខ្លាំង ។

ឥដ្ឋជាច្រើនរាប់រយពាន់ដុំត្រូវបានដាក់តម្រួតគ្នាក្នុងឡឥដ្ឋនីមួយៗ ជាមួយនឹងវត្ថុដែលដុតបញ្ឆេះឡដូចជាអុស កម្ទេចក្រណាត់ឧស្សាហកម្មកាត់ដេរ ឬអង្កាម ។ ជាទូទៅ មានអុសជាច្រើនតម្រៀបគរនៅក្រៅឡឥដ្ឋ ។ គំនរកម្ទេចក្រណាត់ជាច្រើនការុងមាននៅពាសពេញសិប្បកម្ម និងពេញចន្លោះគម្លាតឡឥដ្ឋនីមួយៗ ។

ឡឥដ្ឋត្រូវបានបិទ និងដុតបញ្ឆេះតាមប្រហោងឱ្យកម្តៅឡើងដល់១០០អង្សា ។[១៧] កម្មករប្រឈមនឹងកម្តៅភ្លើងខ្លាំងក្នុងរយៈពេលយូរ ព្រមទាំងមានផេះ ធូលី ផ្សែង និងជាតិពុលចេញពីចំហេះកម្ទេចក្រណាត់ ។ កម្តៅឡឥដ្ឋក៏អាចធ្វើឱ្យទីតាំងការងារដទៃក្តៅផងដែរ ។ ផ្សែងហុយចេញតាមបំពង់បង្ហុយនៅពេលខ្លះមានពណ៌ខ្មៅដោយសារចំហេះកម្ទេចក្រណាត់ ។

បន្ទាប់ពីដុតរួចរាល់ ឥដ្ឋត្រូវបានទុកឱ្យត្រជាក់នៅក្នុងឡ ។ ឥដ្ឋដុតឆ្អិនត្រូវបានជញ្ជូនដាក់លើរទេះវិញ និងដាក់តម្រៀបជាជួររង់ចាំអ្នកទិញ ឬ**ជញ្ជូនដាក់លើរថយន្តដឹកទំនិញ** ។ រថយន្តដឹកឥដ្ឋ ជាទូទៅអាចផ្ទុកឥដ្ឋបាន**ប្រហែល មួយម៉ឺន ដុំ** ហើយការលើកដុំឥដ្ឋដាក់លើរថយន្ត គឺត្រូវការប្រើប្រាស់កំលាំងមនុស្សលើក ដាក់ និងរៀប ម្តងចំនួន ប្រាំបី ដុំឥដ្ឋ ។

កម្មករម្នាក់ ឬសមាជិកមួយគ្រួសារ ជាទូទៅមានតួនាទីបំពេញកិច្ចការងារមួយ ឬផ្នែកមួយក្នុងដំណើរការនៃផលិតកម្មឥដ្ឋ ។ កម្មករជារឿយៗទទួលបានប្រាក់ឈ្នួលលក្ខណៈជាគ្រួសារ ជាជាងលក្ខណៈជាបុគ្គល ហើយប្រាក់ឈ្នួលត្រូវបានគិតតាមចំនួនដុំឥដ្ឋដែលពួកគេផលិតបាន ។ កម្មករទទួលបានប្រាក់ឈ្នួលប្រចាំខែ ជាជាងប្រាក់ឈ្នួលគិតតាមចំនួនដុំឥដ្ឋ ចំពោះការងារណាដែលមានរយៈពេលខ្លី ដូចជាការងារបញ្ឆេះ និងរក្សាកម្តៅឡឥដ្ឋ ឬការងារបញ្ជាម៉ាស៊ីនជីកដីជាដើម ។ កន្លែងស្នាក់នៅរបស់កម្មករ ជាទូទៅត្រូវបានផ្តល់ឱ្យដោយម្ចាស់សិប្បកម្ម ដែលស្ថិតនៅក្នុងទីតាំងសិប្បកម្មផ្ទាល់ និងនៅព័ទ្ធជុំវិញបរិវេណសិប្បកម្ម ។

[១៦] សូមមើលឧទាហរណ៍ដូចជា "ការអភិវឌ្ឍលើទាសភាព៖ ការអភិវឌ្ឍលើទាសភាព៖ ការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារនៅក្នុងសិប្បកម្មផលិតឥដ្ឋនៅកម្ពុជា" របស់អង្គការលីកាដូ ទំព័រទី១៣-១៤ ។ Leonie Kijewski និង Kong Meta, "កុមាររងរបួសដាច់ដៃនៅសិប្បកម្មឡឥដ្ឋកម្ពុជា" វីអូអេ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ អាចរកបាននៅ https://www.voanews.com/a/child-loses-arm-in-cambodia-brick-factory/4839123.html

[១៧] សូមមើលឧទាហរណ៍ដូចជា Brickell et al "ដុំឥដ្ឋលោហិត៖ រឿងរ៉ាវដែលគេមិនដែលប្រាប់អំពីទាសភាពសម័យទំនើប និងការប្រែប្រួលអាកាសធាតុនៅកម្ពុជា"ទំព័រទី៣៨





## កម្មករសិប្បកម្មផលិតឥដ្ឋប្រឈមនឹងហានិភ័យ ព្រោះតែការធ្លាក់ចុះនៃវិស័យនេះ

តម្រូវការឥដ្ឋបានធ្លាក់ចុះយ៉ាងខ្លាំង ដែលបានជះផលប៉ះពាល់ធ្ងន់ធ្ងរដល់សិប្បកម្មផលិតឥដ្ឋក្នុងខេត្តកណ្តាល និងរាជធានីភ្នំពេញ ។ សិប្បកម្មចំនួនប្រាំទីតាំង ដែលអង្គការលីកាដូបានចុះសិក្សា បានបិទអាជីវកម្មជាអចិន្ត្រៃយ៍ ដោយសារគ្មានការបញ្ជាទិញ ។ សិប្បកម្មចំនួនយ៉ាងតិចប្រាំបីទៀតបានកាត់បន្ថយ ឬផ្អាកផលិតកម្ម ដែលក្នុងនោះសិប្បកម្មមួយចំនួន បានផ្អាករហូតដល់រយៈពេល ៦ខែ ។ ដីសិប្បកម្មមួយចំនួនត្រូវបានដាក់លក់ ។

អ្នកផ្តល់បទសម្ភាសន៍បានរាយការណ៍ថា ការថយចុះតម្រូវការនេះបានជះឥទ្ធិពលដ៏ធំធេងក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ មិនត្រឹមតែទៅលើសិប្បកម្មដែលអង្គការលីកាដូបានចុះសិក្សានោះទេ ។ អ្នកផ្តល់បទសម្ភាសន៍ម្នាក់បានពន្យល់ប្រាប់ថាក្នុងចំណោមសិប្បកម្មចំនួន ១០ ទីតាំងដែលនៅជិតៗ មានតែសិប្បកម្មមួយគត់ដែលដំណើរការធម្មតា ហើយសិប្បកម្មស្ទើរតែទាំងអស់ផ្សេងទៀតបានបញ្ឈប់ផលិតកម្ម ។

**ក្នុងចំណោមសិប្បកម្មចំនួន ១០ ទីតាំងដែលនៅជិតៗ មានតែសិប្បកម្មមួយគត់ដែលដំណើរការធម្មតា ។**

តម្រូវការឥដ្ឋបានធ្លាក់ចុះទាបអស់រយៈពេលជាច្រើនឆ្នាំមកហើយ ។[១៨] សំណង់នៅក្នុងទីក្រុងដូចជារាជធានីភ្នំពេញ និងក្រុងព្រះសីហនុ ត្រូវបានផ្អាកអំឡុងពេលមានវិបត្តិនៃជំងឺកូវីដ ហើយវិស័យសំណង់នេះនៅមិនទាន់មានភាពប្រសើរឡើងវិញទាំងស្រុងនោះទេ ។[១៩] ខណៈដែលតម្លៃអាជ្ញាប័ណ្ណអនុញ្ញាតការសាងសង់កើនឡើងនៅដើមឆ្នាំ២០២៣ ដែលជាការឡើងថ្លៃលើកដំបូងតាំងពីឆ្នាំ២០១៩មក[២០] ការងើបឡើងវិញនៃវិស័យសំណង់នៅតែមិនទាន់មានភាពច្បាស់លាស់នៅឡើយ ។ អ្នកផ្តល់ចម្លើយមួយចំនួនបានប្រាប់អង្គការលីកាដូថាក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ តម្លៃឥដ្ឋបានធ្លាក់ចុះពីចន្លោះ ២៧០ ទៅ ៣២០ដុល្លារអាមេរិក ក្នុង១០ ០០០ដុំ ទៅ ១៧០ ទៅ ២១០ដុល្លារអាមេរិក ។ ម្ចាស់សិប្បកម្មផលិតឥដ្ឋខ្លះក៏បានប្រាប់ថាតម្លៃវត្ថុធាតុដើមសម្រាប់ផលិតកម្ម ដូចជាដីឥដ្ឋ និងអុស បានកើនឡើង ។

[១៨] កម្មករបានរាយការណ៍ថាតម្រូវការឥដ្ឋបានធ្លាក់ចុះតាំងពីវិបត្តិជំងឺកូវីដ១៩មក។ សូមមើលផងដែរ Marta Kasztelan and Sam Quashie-Idun, "ត្រូវបានលាតត្រដាង៖ សំណល់ក្រណាត់របស់ណៃខ៍ ខ្លាកស៍ និងម៉ាកល្បីនាំមុខដទៃទៀតត្រូវបានដុតបញ្ចេះឡឥដ្ឋដែលមានជាតិពុលនៅកម្ពុជា" សារព័ត៌មាន Unearthed (អង្គការ Greenpeace ចក្រភពអង់គ្លេស) ថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២ អាចរកបាននៅ https://unearthed.greenpeace.org/2022/08/08/garment-waste-nike-clarks-cambodia-bonded-workers-toxic/ ។ ឃួន ណារីម "ទាសភាពបំណុលនិងពលកម្មកុមារនៅតែមានដដែលនៅតាមក្នុងសិប្បកម្មឡឥដ្ឋ" ខេមបូចា ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១

[១៩] សូមមើលដូចជា ហុល រស្មី និង Lors Liblib "ការឈប់គាំងនៃការងើបឡើងវិញនៃវិស័យអចលនទ្រព្យរបស់កម្ពុជាមានហានិភ័យនៃកង្វះឥណទាន" វីអូអេ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣ អាចរកបាននៅ https://www.voacambodia.com/a/halting-recovery-of-cambodia-s-real-estate-sector-risks-credit-shortage/7073559.html

[២០] "បច្ចុប្បន្នភាពស្ថានភាពសេដ្ឋកិច្ចកម្ពុជា ខែឧសភា ឆ្នាំ២០២៣៖ ការងើបឡើងវិញនៃសេដ្ឋកិច្ចក្រោយវិបត្តិជំងឺកូវីដ១៩" ធនាគារពិភពលោក ទំព័រទី១២ ខែឧសភា ឆ្នាំ២០២៣ អាចរកបាននៅ https://documents1.worldbank.org/curated/en/099051523221517821/pdf/P17734003f2bcf02b0a89500f61b1f3ff7b.pdf

ម្ចាស់សិប្បកម្មឡឥដ្ឋបានផ្តល់ចម្លើយផ្សេងៗ និងជួនកាលមានចម្លើយមួយចំនួនដូចគ្នា ដែលរួមមាន៖

- **យ៉ាងតិចណាស់មានម្ចាស់សិប្បកម្មផលិតឥដ្ឋ បីទីតាំង បានផ្ទេរពលករដែលបញ្ចាំខ្លួនដោះបំណុល ឱ្យទៅធ្វើការងារថ្មី ។** ម្ចាស់សិប្បកម្មឡឥដ្ឋមួយកន្លែងដែលបានកាត់បន្ថយផលិតកម្ម និងបានបើកសិប្បកម្មនៅកន្លែងមួយទៀតក្បែរគ្នា ដែលផលិតវត្ថុផ្សេងពីឥដ្ឋ ។ ពលករសិប្បកម្មផលិតឥដ្ឋដែលបញ្ចាំខ្លួនដោះបំណុលមួយចំនួនឥឡូវនេះកំពុងធ្វើការនៅទីតាំងសិប្បកម្មថ្មីនោះ ។ ម្ចាស់សិប្បកម្មផលិតឥដ្ឋទីពីរ បានចាប់ផ្តើមរកស៊ីរបរកសិកម្មខ្នាតតូចមួយនៅក្នុងទីតាំងសិប្បកម្មផលិតឥដ្ឋ ហើយមានកម្មករម្នាក់ត្រូវបានគេប្រាប់ថាកំពុងធ្វើការងារនោះ ។ ម្ចាស់សិប្បកម្មផលិតឥដ្ឋទីបី មិនព្រមអនុញ្ញាតឱ្យគ្រួសារកម្មករមួយចំនួនចាកចេញពីបរិវេណសិប្បកម្មរហូតទាល់តែពួកគេសងបំណុលអស់ បើទោះជាសិប្បកម្មនោះបានបិទអាជីវកម្មហើយក៏ដោយ ។ គ្រួសារទាំងនេះកំពុងធ្វើការឱ្យម្ចាស់សិប្បកម្មនេះដែលធ្វើអាជីវកម្មតូចតាចមួយចំនួននៅក្បែរបរិវេណសិប្បកម្ម ។
- **កម្មករខ្លះគ្មានប្រាក់ចំណូលនៅសិប្បកម្មផលិតឥដ្ឋ និងមិនត្រូវបានអនុញ្ញាតឱ្យទៅធ្វើការនៅកន្លែងផ្សេង ។** កម្មករមួយចំនួនរាយការណ៍ថាកំពុងជួបបញ្ហាខ្វះខាតហិរញ្ញវត្ថុខ្លាំងដោយសារផលិតកម្មឥដ្ឋមានតិច និងគ្មានចំណូលអ្វីផ្សេងក្រៅពីការបេះបន្លែ ឬប្រមូលខ្យងនៅជុំវិញលក់ ។ ម្ចាស់សិប្បកម្មជាច្រើន បានកាត់បន្ថយប្រាក់ដែលកម្មករអាចខ្ចីបាន ដោយជាទូទៅអាចឱ្យប្រាក់កម្ចីថែមត្រឹម ៥០ ០០០រៀល (ប្រមាណ ១២,៥០ដុល្លារ) តែប៉ុណ្ណោះ បើធៀបទៅនឹងប្រាក់កម្ចីរាប់រយដុល្លារកាលពីមុន ។ នៅពេលដែលកម្មករកាន់តែមិនចង់ជាប់ជំពាក់ជាមួយសិប្បកម្មដោយសារបំណុលកាន់តែច្រើនឡើង កម្មករទាំងនោះរាយការណ៍ប្រាប់ថាពួកគេកាន់តែគ្មានលទ្ធភាពឆ្លើយតបទៅនឹងវិបត្តិនានា ឬទិញអាហារ និងថែទាំសុខភាព ។
- **កម្មករខ្លះត្រូវបានអនុញ្ញាតឱ្យទៅរស់នៅ ឬធ្វើការនៅកន្លែងផ្សេង ក៏ប៉ុន្តែពួកគេត្រូវតែត្រឡប់មកវិញ ។** នេះគឺជាចម្លើយទូទៅជាងគេរបស់ម្ចាស់សិប្បកម្មដែលបានផ្អាក ឬកាត់បន្ថយផលិតកម្ម ។ កម្មករសិប្បកម្មផលិតឥដ្ឋមួយចំនួន បានចាប់ផ្តើមធ្វើការក្នុងរោងចក្រកាត់ដេរ វិស័យសំណង់ កសិកម្ម ឬធ្វើជាអ្នកបើករថយន្តដឹកជញ្ជូន ។ កម្មករខ្លះតម្រូវឱ្យបង់រំលស់បំណុលប្រចាំខែ ។ តាមដឹងមក ម្ចាស់សិប្បកម្មផលិតឥដ្ឋ មានព័ត៌មានទំនាក់ទំនង និងស្គាល់ស្រុកកំណើតរបស់កម្មករ ហើយជឿជាក់ថាកម្មករនឹងត្រឡប់មកសិប្បកម្មវិញនៅពេលហៅមកវិញ ។[២១]
- **យ៉ាងហោចណាស់ ម្ចាស់សិប្បកម្មផលិតឥដ្ឋបីកន្លែង បានលុបចោលបំណុល និងអនុញ្ញាតឱ្យកម្មករចាកចេញពីសិប្បកម្ម ។** សិប្បកម្មទាំងអស់នេះបានបិទអាជីវកម្មជាអចិន្ត្រៃយ៍ ។ ម្ចាស់សិប្បកម្មពីរកន្លែងអនុញ្ញាតឱ្យកម្មករទាំងអស់ចាកចេញពីសិប្បកម្ម និងលុបចោលបំណុលទាំងអស់របស់ពួកគេ ។ ម្ចាស់សិប្បកម្មទីបី បានលុបចោលបំណុលកម្មករដែលមានវ័យចំណាស់តែប៉ុណ្ណោះ ដោយយល់ឃើញថាពួកគេលែងផ្តល់ជាកម្លាំងពលកម្ម ឬលែងមានលទ្ធភាពសងបំណុល ។ ម្ចាស់សិប្បកម្មផលិតឥដ្ឋទីបួន គិតថាសិប្បកម្មរបស់ពួកគេនឹងបិទក្នុងពេលឆាប់ៗ ។ ពួកគេក៏បានប្រាប់ពីបំណងលុបចោលបំណុលរបស់កម្មករផងដែរ ។ អំពើនៃការលុបចោលបំណុលទាំងនេះ បង្ហាញឱ្យឃើញថា ការបញ្ឈប់ការបញ្ចាំខ្លួនដោះបំណុលនៅសិប្បកម្មផលិតឥដ្ឋ គឺអាចធ្វើទៅបាន ។



[២១] ក្រៅពីកត្តាដែលបានពិភាក្សានៅទំព័រ ១៦ ដល់ ១៧ ដែលចងកម្មករជាប់នឹងសិប្បកម្មផលិតឥដ្ឋ កម្មករសិប្បកម្មផលិតឥដ្ឋច្រើនតែសម្តែងនូវភាពស្មោះស្ម័គ្រ ឬគុណធម៌ចំពោះម្ចាស់សិប្បកម្ម ដោយសារជំនឿ និងសាសនាផង ។ ទាំងនេះអាចបង្កើនភាគរយនៃការវិលត្រឡប់របស់កម្មករ មកសិប្បកម្មវិញនៅពេលដែលហៅមកវិញ ។ សូមមើល Laurie Parsons និង Katherine Brickell "ព្រលឹងវិញ្ញាណក្នុងម៉ាស៊ីន៖ ឆ្ពោះទៅកាន់ភូមិសាស្ត្រនៃជំនឿសាសនាមួយដែលពោរពេញដោយការបញ្ចាំខ្លួនដោះបំណុល និង(អ)ចល័តភាពនៃពលកម្មនៅឡឥដ្ឋកម្ពុជា" កំណត់ត្រារបស់វិទ្យាស្ថាននៃអ្នកភូមិសាស្ត្រអង់គ្លេស ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០

## ការបញ្ចាំខ្លួនដោះបំណុលគឺជាទម្រង់មួយនៃទាសភាពសម័យទំនើប

ការបញ្ចាំខ្លួនដោះបំណុលគឺជាទម្រង់មួយនៃទាសភាពសម័យទំនើប ដែលកើតមាននៅពេលកម្លាំងពលកម្មរបស់បុគ្គលម្នាក់ត្រូវបានប្រើប្រាស់ដើម្បីទូទាត់សងបំណុល ប៉ុន្តែតម្លៃនៃកម្លាំងពលកម្មនោះមិនត្រូវបានឆ្លុះបញ្ចាំងក្នុងការទូទាត់សំណងនោះទេ ឬរយៈពេលឬប្រភេទនៃការងារមិនមានការកំណត់ច្បាស់លាស់ដើម្បីបញ្ចប់ការងារពលកម្ម ។[២២] ជាលទ្ធផល "ពលករដែលបញ្ចាំខ្លួនដោះបំណុល ច្រើនតែជាប់អន្ទាក់ការងារដែលមានប្រាក់ឈ្នួលទាបខ្លាំង ឬក្នុងករណីខ្លះមិនទទួលបានប្រាក់ឈ្នួល ធ្វើឱ្យពួកគេគ្មានលទ្ធភាពសងប្រាក់កម្ចី ឬប្រាក់បើកទុកមុន បើទោះជាតម្លៃកម្លាំងពលកម្មរបស់ពួកគេមានទំហំច្រើនជាងចំនួនប្រាក់កម្ចីក្តី" ។[២៣]

ការបញ្ចាំខ្លួនដោះបំណុលត្រូវបានហាមឃាត់ដាច់ខាតដោយច្បាប់កម្ពុជា និងអន្តរជាតិ ។ ច្បាប់កម្ពុជាស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ហាមឃាត់ទាំង "ការនាំចេញដោយមិនស្របច្បាប់" និង"ការជ្រើសរើសដោយមិនស្របច្បាប់" ដោយមានគោលដៅកេងប្រវ័ញ្ច ដែលរួមមានយ៉ាងច្បាស់នូវការបញ្ចាំខ្លួនដើម្បីដោះបំណុល ។[២៤] បទចោទប្រកាន់ទាំងនេះអាចអនុវត្តចំពោះម្ចាស់សិប្បកម្មបាន ។[២៥] "ការនាំចេញដោយមិនស្របច្បាប់" មានន័យថាការធ្វើឱ្យមនុស្សម្នាក់ផ្លាស់ទីពីកន្លែង ដែលគេកំពុងរស់នៅទៅកាន់ទីកន្លែងដទៃដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ជនប្រព្រឹត្តនោះ តាមមធ្យោបាយបង្ខិតបង្ខំ គម្រាមកំហែង បោកបញ្ឆោត បំពានដោយអំណាច ឬលួងលោម ។[២៦] ការយល់ព្រមរបស់បុគ្គលម្នាក់ចំពោះការផ្លាស់ទី មិនទាក់ទងឡើយ បើសិនជាមធ្យោបាយណាមួយទាំងនេះត្រូវបានប្រើប្រាស់ ។[២៧] "ការជ្រើសរើសដោយមិនស្របច្បាប់" សំដៅបញ្ចុះបញ្ចូល ការជួល ឬការឱ្យជនណាមួយបម្រើការក្រោមទម្រង់នៃការកេងប្រវ័ញ្ចតាមមធ្យោបាយបោកបញ្ឆោត បំពានដោយអំណាច ការបង្ខាំងខ្លួន ការប្រើប្រាស់កម្លាំង ការគម្រាមកំហែង ឬមធ្យោបាយបង្ខិតបង្ខំផ្សេងទៀត ។[២៨] ទោសទណ្ឌនៃបទល្មើសទាំងពីរនេះ គឺការជាប់ពន្ធនាគារពី ៧ឆ្នាំ ទៅ ១៥ឆ្នាំ បើសិនជាជនដែលត្រូវបានគេកេងប្រវ័ញ្ចជាមនុស្សពេញវ័យ និងជាប់ពន្ធនាគារពី ១៥ឆ្នាំ ទៅ ២០ឆ្នាំ បើសិនជាជនរងគ្រោះជាអនីតិជន ។[២៩]

ច្បាប់ការងាររបស់កម្ពុជា ក៏ហាមឃាត់ពលកម្មដោយបង្ខំ និងការជួលមនុស្សឱ្យធ្វើការដើម្បីដោះបំណុល ។[៣០] ច្បាប់នេះមានការដាក់ពិន័យតិចតួច ឬផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររហូតដល់មួយខែ ចំពោះការអនុវត្តពលកម្មដោយបង្ខំ និងដាក់ពិន័យតិចតួចចំពោះការជួលមនុស្សឱ្យធ្វើការដើម្បីដោះបំណុល ។[៣១] ការបញ្ចាំខ្លួនដោះបំណុលក៏មិនចុះសម្រុងជាមួយនឹងមាត្រាមួយចំនួនក្នុងរដ្ឋធម្មនុញ្ញ និងក្រមព្រហ្មទណ្ឌផងដែរ ។[៣២]

ឧបករណ៍ច្បាប់អន្តរជាតិជាច្រើនដែលផ្តល់សច្ចាប័នដោយកម្ពុជា ក៏ហាមឃាត់ពលកម្មដោយបង្ខំ និងពលកម្មដោះបំណុលផងដែរ ។ ឧទាហរណ៍មានដូចជា អនុសញ្ញាបន្ថែមស្តីពីការលុបចោលទាសភាព ការជួញដូរទាសករ និងទំនៀមទម្លាប់ និងការអនុវត្តស្រដៀងនឹងទាសភាព ទាមទារឱ្យលុបបំបាត់ចោលទាំងស្រុងនៃពលកម្មដើម្បីដោះបំណុល ។[៣៣]

[២២] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីទម្រង់សម័យថ្មីនៃទាសភាព ព្រមទាំងមូលហេតុ និងផលវិបាក A/HRC/33/46 កថាខណ្ឌទី៥ ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៦ អាចរកបាននៅ https://daccess-ods.un.org/access.nsf/Get?OpenAgent&DS=A/HRC/33/46&Lang=E

[២៣] ដូចខាងលើ កថាខណ្ឌទី៦

[២៤] មាត្រា ៨, ១០ និង១២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ច្បាប់ប្រឆាំងការជួញដូរ)

[២៥] សូមមើល "ការអភិវឌ្ឍលើទាសភាព៖ ការអភិវឌ្ឍលើទាសភាព៖ ការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារនៅក្នុងសិប្បកម្មផលិតឥដ្ឋនៅកម្ពុជា" របស់អង្គការលីកាដូ ទំព័រទី១៦

[២៦] មាត្រា ៨(១) នៃច្បាប់ប្រឆាំងការជួញដូរ

[២៧] មាត្រា ១០ នៃច្បាប់ប្រឆាំងការជួញដូរ

[២៨] មាត្រា ១២ នៃច្បាប់ប្រឆាំងការជួញដូរ

[២៩] មាត្រា ១០ និងមាត្រា ១២ នៃច្បាប់ប្រឆាំងការជួញដូរ

[៣០] មាត្រា ១៥-១៦ នៃច្បាប់ស្តីពីការងារ

[៣១] មាត្រា ៣៦៩-៣៧០ នៃច្បាប់ស្តីពីការងារ

[៣២] មាត្រា ៣១ ៣២ ៣៦ ៣៨ និង៤៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ មាត្រា ២៧៤ នៃក្រមព្រហ្មទណ្ឌ

[៣៣] មាត្រា ១(ក) នៃអនុសញ្ញាបន្ថែមស្តីពីការលុបចោលទាសភាព ការជួញដូរទាសករ និងទំនៀមទម្លាប់ និងការអនុវត្តស្រដៀងនឹងទាសភាព។ សូមមើលផងដែរ អនុញ្ញារបស់អង្គការពលកម្មអន្តរជាតិស្តីពីពលកម្មដោយបង្ខំ ឆ្នាំ១៩៣០ (លេខ ២៩)






## ការបញ្ចាំខ្លួនដោះបំណុលនៅតែមានរីករាលដាលដដែល

ការបញ្ចាំខ្លួនដោះបំណុលនៅតែមានរីករាលដាលដដែលនៅក្នុងឧស្សាហកម្មផលិតឥដ្ឋនៅកម្ពុជា ទោះជាតម្រូវការឥដ្ឋមានតិចតួចក្តី ។ នៅតាមសិប្បកម្មផលិតឥដ្ឋដែលមិនបានបិទអាជីវកម្ម គ្រប់កម្មករដែលបានចូលរួមបទសម្ភាសន៍ទាំងអស់ មានជំពាក់បំណុលម្ចាស់សិប្បកម្មផលិតឥដ្ឋ ដែលម្ចាស់សិប្បកម្មទាំងនោះប្រើប្រាស់មធ្យោបាយនានា ដើម្បីធានាថាគ្រួសារកម្មករនៅចងជាប់ទៅនឹងឧស្សាហកម្មនេះ ។

### បំណុលដែលកាន់តែកើនឡើង

កម្មករដែលបានចូលរួមបទសម្ភាសន៍ជាមួយអង្គការលីកាដូ បានរស់នៅក្នុងសិប្បកម្មផលិតឥដ្ឋអស់រយៈពេលជាមធ្យម ១៨ ឆ្នាំ មកហើយ ។ ពួកគេភាគច្រើនបានរាយការណ៍ថាដំបូងឡើយពួកគេបានផ្លាស់មករស់នៅក្នុងសិប្បកម្មផលិតឥដ្ឋតាមសមាជិកគ្រួសារ ឬអ្នកជិតខាង បន្ទាប់មកក៏បានយកកម្ចីលើកទីមួយពីម្ចាស់សិប្បកម្មផលិតឥដ្ឋដើម្បីយកទៅបង់ថ្លៃព្យាបាលជំងឺ សងម្ចាស់បំណុលឯកជន ទិញដី ទិញម៉ូតូ ឬជួយសមាជិកគ្រួសាររបស់ពួកគេ ។

បំណុលមានជំពាក់ដោយកម្មករម្នាក់ៗ ឬដោយប្ដីប្រពន្ធ ឬដោយគ្រួសារ ដែលអ្នកទាំងនោះត្រូវធ្វើការទាំងអស់គ្នាដើម្បីទទួលបានប្រាក់ចំណូលមួយ និងសងបំណុលមួយ ។ បំណុលដែលកម្មករជំពាក់ម្ចាស់សិប្បកម្មមានទំហំចាប់ពី ១ លាន ទៅ ៤០ លានរៀល (ប្រហែល ២៥០ ដុល្លារ ទៅ ១០ ០០០ ដុល្លារ) ដែលបំណុលភាគច្រើនមានចន្លោះពី ៨លាន ទៅ ១២ លានរៀល (ប្រហែល ២ ០០០ ដុល្លារ ទៅ ៣ ០០០ ដុល្លារ) ។ ម្ចាស់សិប្បកម្មមួយចំនួនកាត់យកសំណងបំណុលចេញពីប្រាក់ចំណូលរបស់កម្មករតែម្ដង ។ នៅសិប្បកម្មដទៃទៀត កម្មករទទួលបានប្រាក់ឈ្នួល និងអាចស្ម័គ្រចិត្តទូទាត់សងបំណុល ។ ទោះជាយ៉ាងនេះក្តី កម្មករជាច្រើនដែលអង្គការលីកាដូបានសម្ភាស នៅមិនទាន់បានកាត់បន្ថយបំណុលរបស់ពួកគេបានច្រើននៅឡើយទេ ដោយសារទទួលបានប្រាក់ឈ្នួលទាបពេកសម្រាប់តម្លៃពលកម្មរបស់ពួកគេ ។

**កម្មករជាច្រើនដែលអង្គការលីកាដូបានសម្ភាស នៅមិនទាន់បានកាត់បន្ថយបំណុលរបស់ពួកគេបានច្រើននៅឡើយទេ ដោយសារទទួលបានប្រាក់ឈ្នួលទាបពេកសម្រាប់តម្លៃពលកម្មរបស់ពួកគេ ។**

អ្នកផ្ដល់ចម្លើយភាគច្រើន យកកម្ចីបន្ថែមខណៈពេលរស់នៅក្នុងសិប្បកម្មផលិតឥដ្ឋ ដើម្បីចំណាយលើជីវភាពរស់នៅ ដូចជាចំនីអាហារ និងការថែទាំសុខភាពនៅពេលឈឺស្កាត់ រងរបួស និងសម្រាលកូន ដែលធ្វើឱ្យការបញ្ចាំខ្លួនដោះបំណុលនៅបន្តមាន ។ កម្មករជាច្រើនបានយកកម្ចីបន្ថែមជាញឹកញាប់នៅពេលប្រាក់ចំណូលរបស់ពួកគេបានថយចុះដោយសារតែការផ្អាកផលិតកម្ម ។ សិប្បកម្មជារឿយៗផ្អាកការផលិតមិនត្រឹមតែនៅពេលតម្រូវការឥដ្ឋមានតិចតួចប៉ុណ្ណោះទេ ថែមទាំងនៅក្នុងរដូវភ្លៀងផងដែរខណៈដែលសិប្បកម្មគ្មានដំបូលមិនអាចហាលឥដ្ឋបាន ។ កម្មករជាច្រើនបានរាយការណ៍ថាធ្លាប់ផ្លាស់ទៅសិប្បកម្មផ្សេងទៀត ដោយសារពួកគេត្រូវការប្រាក់កម្ចីធំដើម្បីយកមកទូទាត់សងបង្គ្រប់បំណុលចាស់ និងទុកប្រាក់ដែលនៅសល់សម្រាប់ចំណាយ ។

ការបញ្ចាំខ្លួនដោះបំណុលនៅសិប្បកម្មផលិតឥដ្ឋ មិនមានត្រឹមតែជាមួយម្ចាស់សិប្បកម្មនោះទេ ។ ម្ចាស់រថយន្តដឹកជញ្ជូន ដែលមិនចាំបាច់មានទំនាក់ទំនងផ្លូវការជាមួយសិប្បកម្ម ក៏ផ្តល់កម្ចីស្រដៀងគ្នាទៅឱ្យអ្នកបើករថយន្តសម្រាប់ចំណាយលើសេវាធ្វើប័ណ្ណបើកបរ និងអត្តសញ្ញាណប័ណ្ណ ។ ជាឧទាហរណ៍ មានគ្រួសារជំពាក់បំណុលម្ចាស់សិប្បកម្មផលិតឥដ្ឋមួយ បានប្រាប់ថាពួកគេក៏មានសមាជិកគ្រួសារជំពាក់បំណុលម្ចាស់រថយន្តដឹកជញ្ជូនផងដែរ ។

# ប្រាក់ចំណូលជាមធ្យម

ប្រាក់ចំណូលរបស់កម្មករសិប្បកម្មផលិតឥដ្ឋមានការប្រែប្រួលខ្លាំងដោយសារការងារមានលក្ខណៈមិនទៀងទាត់ ហើយប្រាក់ឈ្នួលត្រូវបានគិតទៅតាមចំនួនឥដ្ឋ ។ កម្មករខ្លះបានរាយការណ៍ថារកចំណូលប្រចាំថ្ងៃបានពីចន្លោះ ១០ ០០០ រៀល ទៅ ៣០ ០០០ រៀល (ប្រហែល ២,៥ ដុល្លារ ទៅ ៧,៥ ដុល្លារ) ក្នុងម្នាក់ នៅអំឡុងពេលដែលមានផលិតកម្មឥដ្ឋ ។ អ្នកផ្សេងទៀតបានរាយការណ៍ថាប្រាក់ចំណូលរបស់ពួកគេត្រូវបានគិតជាលក្ខណៈគ្រួសារសម្រាប់ពលកម្មរយៈពេលជាច្រើនសប្តាហ៍ ឬខែ ។ ម្ចាស់សិប្បកម្មមួយចំនួនប្រើវិធីសាស្ត្រកាត់ប្រាក់ឈ្នួលរបស់កម្មករដើម្បីរំលស់បំណុល ឬសងការខូចខាតឥដ្ឋជាដើម ។

ជាទូទៅ តម្លៃកម្លាំងពលកម្មគិតតាមចំនួនឥដ្ឋសម្រាប់ការងារជាក់លាក់មាន៖

| ១២ រៀល ($0.00៣) | ៣ រៀល ($0.000៨) | ៣ រៀល ($0.000៨) | ២ រៀល ($0.000៥) |
|---|---|---|---|
| ក្នុងមួយដុំ សម្រាប់ការផលិតឥដ្ឋដោយម៉ាស៊ីនបញ្ជាដោយដៃ និងការជញ្ជូន រុញ និងតម្រៀបឥដ្ឋហាល ។ | ក្នុងមួយដុំ សម្រាប់ការជញ្ជូនឥដ្ឋពីម៉ាស៊ីនបញ្ជាស្វ័យប្រវត្តិ រុញ និងតម្រៀបហាល ។ | ក្នុងមួយដុំ សម្រាប់ការជញ្ជូនឥដ្ឋពីឡដុត ។ | ក្នុងមួយដុំ សម្រាប់ការលើកដាក់ និងលើកចុះឥដ្ឋពីរថយន្តដឹកជញ្ជូន ។ |

## *ប្រាក់ឈ្នួលទាប និងបំណុលដែលមិនអាចគេចផុត*

*សុភា* ដែលជាកម្មករសិប្បកម្មផលិតឥដ្ឋម្នាក់ បានពន្យល់ប្រាប់ថាគ្រួសារគាត់ដែលមានសមាជិកបួននាក់ រួមមានកូនពីរនាក់អាយុ ១៥ឆ្នាំ ទៅ១៧ឆ្នាំ ធ្វើការងារលើកជញ្ជូន រុញ និងរៀបឥដ្ឋហាល ។ នៅរដូវកាលមមាញឹកខ្លាំង គ្រួសារគាត់ចាប់ផ្តើមការងារតាំងពីម៉ោង ២ព្រឹក ហើយធ្វើការរហូតដល់ទៅ ១១ ម៉ោងក្នុងមួយថ្ងៃ ដោយគ្មានថ្ងៃសម្រាកចុងសប្តាហ៍ ឬថ្ងៃឈប់បុណ្យឡើយ ។*

*គ្រួសារនេះរកចំណូលរួមគ្នាបាន ៧៥០ ០០០ រៀល (ប្រហែល ១៨៧,៥០ ដុល្លារ) ជាមធ្យមក្នុងមួយខែ ។ ក៏ប៉ុន្តែ ម្ចាស់សិប្បកម្មផលិតឥដ្ឋ កាត់ប្រាក់ចំណូលរបស់គ្រួសារនេះដើម្បីរំលស់បំណុល ។ ដូច្នេះហើយ គ្រួសារគាត់ជួលកាលទទួលបានតែ ២០០ ០០០ រៀល (ប្រហែល ៥០ ដុល្លារ) តែប៉ុណ្ណោះ ក្នុងមួយខែ ។*

*ដោយមានចំណូលតិចតួចសម្រាប់ជីវភាពរស់នៅ គ្រួសារនេះតែងតែត្រូវបង្ខំចិត្តយកប្រាក់កម្ចីបន្ថែម ។ សុភារាយការណ៍ប្រាប់ថាគាត់បានរស់នៅ និងធ្វើការនៅសិប្បកម្មចំនួន ១០កន្លែងហើយ ក្នុងរយៈពេល ៣០ឆ្នាំ ដែលគាត់បានជំពាក់បំណុលឧស្សាកម្មនេះ ហើយគ្រួសារគាត់នៅសល់បំណុលជិត ២ ០០០ ដុល្លារទៀត ។*

** ឈ្មោះត្រូវបានប្តូរ*





## កម្មករជាប់អន្ទាក់

កម្មករមិនត្រូវបានគេឃុំខ្លួននៅសិប្បកម្មផលិតឥដ្ឋនោះទេ ក៏ប៉ុន្តែម្ចាស់សិប្បកម្មប្រើយុទ្ធសាស្ត្រផ្សេងៗជូនកាលថែមទាំងទទួលបានជំនួយពីអាជ្ញាធរ ដើម្បីធានាថាកម្មករបន្តចងជាប់នឹងសិប្បកម្មនេះ ។ បើទោះជាយុទ្ធសាស្ត្រជាក់លាក់នីមួយៗដែលមានរៀបរាប់ដូចខាងក្រោម មិនត្រូវបានអនុវត្តនៅគ្រប់សិប្បកម្មទាំងអស់ក៏ដោយ ក៏កម្មករជាច្រើនបានរាយការណ៍ដូចគ្នាអំពីការយល់ឃើញរបស់ពួកគេថា ពួកគេមិនអាចចាកចេញពីសិប្បកម្មផលិតឥដ្ឋ ឬទៅធ្វើការនៅកន្លែងផ្សេងបានទេ រហូតទាល់តែសងបំណុលគ្រប់ចំនួន ។

## ការចូលរួមរបស់អាជ្ញាធរ

អ្នកផ្តល់បទសម្ភាសន៍នៅសិប្បកម្មផលិតឥដ្ឋចំនួនបួនទីតាំង បានរាយការណ៍ថាមានវត្តមានមន្ត្រីនគរបាលនៅពេលកម្មករចុះហត្ថលេខា ឬផ្តិតមេដៃលើកិច្ចសន្យាផ្តល់ប្រាក់កម្ចីជាមួយម្ចាស់សិប្បកម្មផលិតឥដ្ឋ ។ កម្មករម្នាក់ទៀតបានរាយការណ៍ថាបានចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ប្រាក់កម្ចីនៅផ្ទះមេភូមិ ។ កម្មករមួយចំនួនក៏ត្រូវបានគេថតរូបរាល់ពេលទទួលប្រាក់កម្ចីធំៗ ។ វិធានការទាំងនេះ បង្កើតអារម្មណ៍មួយថាកិច្ចសន្យាផ្តល់ប្រាក់កម្ចីទាំងនេះមានភាពស្របច្បាប់ ហើយកម្មករនឹងប្រព្រឹត្តល្មើសនឹងច្បាប់បើសិនជាពួកគេមិនបន្តនៅសិប្បកម្មផលិតឥដ្ឋរហូតទាល់តែទូទាត់សងបំណុលគ្រប់ចំនួនវិញ ។

កម្មករស្រីម្នាក់ក៏បានប្រាប់ថាកម្លាំងនគរបាលជួយម្ចាស់សិប្បកម្មផលិតឥដ្ឋតាមរកកម្មករមកវិញ បើសិនជាពួកគេព្យាយាមចាកចេញពីសិប្បកម្ម ។ គាត់បានប្រាប់ថាគាត់ភ័យខ្លាចគេតាមចាប់ បើសិនជាគាត់ចាកចេញពីសិប្បកម្មដោយសារគាត់យល់ថាម្ចាស់សិប្បកម្មនឹងដាក់ពាក្យបណ្តឹងទៅនគរបាលឱ្យតាមចាប់គាត់មកវិញ ។

**មានវត្តមានមន្ត្រីនគរបាល នៅពេលកម្មករចុះហត្ថលេខា ឬផ្តិតមេដៃលើកិច្ចសន្យាផ្តល់ប្រាក់កម្ចី ។**

ម្ចាស់សិប្បកម្មផលិតឥដ្ឋមួយចំនួនដកទុកប័ណ្ណកម្មសិទ្ធិដីធ្លី អត្តសញ្ញាណប័ណ្ណ និងសៀវភៅគ្រួសាររបស់កម្មករ[៣៤] ដើម្បីចងពួកគេឱ្យកាន់តែជាប់នឹងសិប្បកម្ម ។ គ្រួសារនៅសិប្បកម្មផលិតឥដ្ឋមួយចំនួន ក៏បានរាយការណ៍ថាពួកគេមិនត្រូវបានអនុញ្ញាតឱ្យចាកចេញពីបរិវេណសិប្បកម្មក្នុងពេលជាមួយគ្នាឡើយ ។ យ៉ាងហោចសមាជិកគ្រួសារម្នាក់ត្រូវនៅក្នុងទីតាំងសិប្បកម្ម ក្រោមទម្រង់មួយនៃការដាក់មនុស្សធ្វើជា "វត្ថុបញ្ចាំ" ដើម្បីធានាថាសមាជិកដទៃនឹងត្រឡប់មកវិញ ។ ការកំហិតបែបនេះអាចបន្ធូរបន្ថយបាននៅពេលកម្មករទទួលបានទំនុកចិត្តពីម្ចាស់សិប្បកម្មបន្ទាប់ពីបានធ្វើការនៅសិប្បកម្មអស់ជាច្រើនឆ្នាំតែប៉ុណ្ណោះ ។ ថ្វីត្បិតយ៉ាងនេះក្តី កម្មករមួយចំនួនបានទទួលស្គាល់ថា បើទោះជាពួកគេត្រូវបានអនុញ្ញាតឱ្យទៅលេងផ្ទះក៏ដោយ ក៏ពួកគេមិនដែលមានប្រាក់គ្រប់គ្រាន់ទៅលេងផ្ទះក្នុងរយៈពេលយ៉ាងហោចណាស់ប៉ុន្មានឆ្នាំកន្លងមកនេះ ។

បន្ថែមពីលើវិធីសាស្ត្រខាងលើនេះ ម្ចាស់សិប្បកម្មមួយចំនួនខិតខំតាមរកកម្មករដែលរត់ចេញពីសិប្បកម្មផលិតឥដ្ឋនិងមិនទាន់សងបំណុលរួច ហើយដាក់សម្ពាធឱ្យពួកគេត្រូវសងបំណុល ឬក៏ត្រូវត្រឡប់មកក្នុងទីតាំងសិប្បកម្មវិញ រីឯម្ចាស់សិប្បកម្មខ្លះទៀតត្រូវបានគេប្រាប់ថា មិនបានចាត់វិធានការតាមរកកម្មករដែលចាកចេញនោះទេ ។ ជារួម តម្រូវការឥដ្ឋទាប បើទោះជាសិប្បកម្មនៅដំណើរការក្តី បានកាត់បន្ថយយ៉ាងគ្រាស់ក្រៃលនូវចំនួនគ្រួសារដែលរស់នៅក្នុងសិប្បកម្មជាច្រើនកន្លែង ដែលអង្គការលីកាដូបានចុះសិក្សា មូលហេតុអាចដោយសារកម្មករត្រូវបានអនុញ្ញាតឱ្យចាកចេញ ឬក៏ពួកគេបានចាកចេញដោយគ្មានការអនុញ្ញាត ។ កម្មករបានរាយការណ៍ជារឿយៗថាចំនួនគ្រួសាររស់នៅក្នុងសិប្បកម្ម បានថយចុះយ៉ាងហោចពាក់កណ្តាល ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក ហើយនៅក្នុងករណីពិសេសមួយចំនួនគ្រួសារបានធ្លាក់ពី ៥០ ឬ ៦០គ្រួសារ មកត្រឹមតែ ១៤ គ្រួសារប៉ុណ្ណោះ ។

គ្មានកម្មករណាម្នាក់ដែលអង្គការលីកាដូបានសម្ភាស សម្តែងនូវចេតនារត់គេចពីបំណុលរបស់ពួកគេឡើយ ។ កម្មករមួយចំនួន បានលើកឡើងពីទឹកចិត្តល្អរបស់ម្ចាស់សិប្បកម្ម បន្ទោសខ្លួនឯងចំពោះភាពជាប់ជំពាក់បំណុល ឬ សម្តែងការដឹងគុណចំពោះកម្ចីឥតការប្រាក់ និងការផ្តល់ទីកន្លែងឱ្យស្នាក់នៅ និងទឹកភ្លើងប្រើប្រាស់ ។ កម្មករខ្លះក៏បាននិយាយថាត្រូវតែអត់ធ្មត់សងបំណុល បើទោះជាពួកគេត្រូវចំណាយពេលអស់មួយជីវិតក៏ដោយ ។ កម្មករបានបញ្ជាក់ពីអារម្មណ៍ទាំងនេះនៅក្នុងកិច្ចសម្ភាសន៍ដែលមានលក្ខណៈជាបុគ្គល ក៏ដូចជាកិច្ចសម្ភាសន៍ដែលមានអ្នកផ្សេងផងដែរ ហើយចម្លើយទាំងនេះមានភាពស៊ីចង្វាក់គ្នាទៅនឹងការរកឃើញនៃការស្រាវជ្រាវពីមុនៗ ។[៣៥] ក៏ប៉ុន្តែ កម្មករជាច្រើននាក់បានប្រាប់ថាជីវិតរបស់ពួកគេមានការលំបាក ពួកគេចង់ចាកចេញពីឧស្សាហកម្មផលិតឥដ្ឋ ឬប្រាប់ថាម្ចាស់សិប្បកម្មមានភាពអត្តានិយម ។ ពួកគេទាំងនោះសង្ឃឹមថានៅពេលសិប្បកម្មនេះបិទអាជីវកម្ម បំណុលរបស់ពួកគេអាចនឹងត្រូវបានលុបចោល ហើយពួកគេអាចត្រឡប់ទៅស្រុកកំណើតវិញ មានដីធ្លីផ្ទាល់ខ្លួន និងឱ្យកូនចៅមានអនាគតផុតឆ្ងាយពីសិប្បកម្មផលិតឥដ្ឋ ។



[៣៤] សៀវភៅគ្រួសារនៅកម្ពុជាជាឯកសារបញ្ជាក់អត្តសញ្ញាណ និងមានផ្ទុកព័ត៌មានផ្ទាល់ខ្លួនរបស់សមាជិកគ្រួសារនីមួយៗ រួមទាំងទំនាក់ទំនងរបស់ពួកគេ ឈ្មោះ និងថ្ងៃខែឆ្នាំកំណើត។

[៣៥] "ការអភិវឌ្ឍលើទាសភាព៖ ការអភិវឌ្ឍលើទាសភាព៖ ការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារនៅក្នុងសិប្បកម្មផលិតឥដ្ឋនៅកម្ពុជា" របស់អង្គការលីកាដូ ទំព័រទី ៦។ Parsons និង Brickell "ព្រលឹងវិញ្ញាណក្នុងម៉ាស៊ីន៖ ឆ្ពោះទៅកាន់ភូមិសាស្ត្រនៃជំនឿសាសនាមួយដែលពោរពេញដោយការបញ្ចាំខ្លួនដោះបំណុល និង(អ)ចល័តភាពនៃពលកម្មនៅឡឥដ្ឋកម្ពុជា"

# ពលកម្មកុមារនៅតែបន្តមាន

កុមារអាយុពី ៩ឆ្នាំ ទៅ ១៧ឆ្នាំ នៅតែបន្តធ្វើការងារក្រោមទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ តាមសិប្បកម្មផលិតឥដ្ឋនៅកម្ពុជា ។[៣៦] គ្រួសារជាច្រើនបានរាយការណ៍ថាការងារក្នុងសិប្បកម្មផលិតឥដ្ឋមានភាពលំបាកសម្រាប់កុមារ ដោយសារជាប្រភេទការងារតម្រូវឲ្យមានការលើកដាក់ និងដឹកជញ្ជូនឥដ្ឋធ្ងន់ៗ និងមានកម្ដៅហួសកម្រិត ។ អង្គការលីកាដូ បានសង្កេតឃើញកុមារធ្វើការនៅសិប្បកម្មផលិតឥដ្ឋចំនួនពីរកន្លែង និងទទួលបានការរាយកាណ៍អំពីពលកម្មកុមារនៅទីតាំងសិប្បកម្មចំនួនបួនផ្សេងទៀត ។

ការងារដែលធ្វើដោយកុមារអាយុពី ១៥ឆ្នាំ ទៅ ១៧ឆ្នាំ ត្រូវបានគេរាយការណ៍ឱ្យដឹងច្រើនជាងការងារដែលធ្វើដោយកុមារមានវ័យក្មេងជាងនេះ ។ នេះអាចដោយសារកម្មករដឹងថា ពលកម្មដោយកុមារអាយុក្រោម ១៥ឆ្នាំ ត្រូវបានហាមឃាត់ដោយច្បាប់ ។[៣៧] ទោះយ៉ាងនេះក្ដី កុមារអាយុក្រោម ១៥ឆ្នាំ ជាក់ស្ដែងនៅតែបន្តធ្វើការនៅតាមសិប្បកម្មផលិតឥដ្ឋ ។ នៅទីតាំងសិប្បកម្មមួយកន្លែង អង្គការលីកាដូបានសង្កេតឃើញមានយ៉ាងហោចកុមារចំនួន ១០នាក់ អាយុចន្លោះពី ១២ឆ្នាំ ទៅ១៧ឆ្នាំ ជញ្ជូនដុំឥដ្ឋធ្ងន់ៗជាច្រើនពីខ្សែសង្វាក់ផលិតរបស់ម៉ាស៊ីនដាក់លើរទេះរុញ ។ ក្មេងទាំងនោះធ្វើការនៅក្រោមដំបូលប្លាស្ទិក ក្បែរឡឥដ្ឋកំពុងឆេះដែលធ្វើឱ្យបរិយាកាសជុំវិញមានកម្ដៅខ្លាំងហួសកម្រិត ។ កម្មកររួមទាំងកុមារត្រូវបានសង្កេតឃើញថាហូរញើសយ៉ាងសស្រាក់សស្រាំ ។[៣៨] កម្មករមួយចំនួនរួមទាំងកុមារ ក៏បានរាយការណ៍ថាធ្វើការច្រើនម៉ោងក្នុងរដូវកាលមមាញឹកខ្លាំង ជួនកាលធ្វើការនៅពេលយប់ផងដែរ ដោយគ្មានថ្ងៃសម្រាកនៅចុងសប្ដាហ៍ ឬថ្ងៃសម្រាកបុណ្យឡើយ ។[៣៩] គ្រួសារនៅសិប្បកម្មចំនួនពីរទីតាំង បានរាយការណ៍ថាកុមារអាយុពី ១៥ឆ្នាំឡើង ចាប់ផ្ដើមធ្វើការតាំងពីព្រលឹមចាប់ពីម៉ោង១ ឬ ២ព្រឹក ដើម្បីចៀសកម្ដៅពេលថ្ងៃត្រង់ ។[៤០]

ការបញ្ចាំខ្លួនដោះបំណុល ការគិតប្រាក់ឈ្នួលតាមចំនួនដុំឥដ្ឋ និងប្រាក់ចំណូលទាប គឺជាឫសគល់នៃពលកម្មកុមារ ។ ទាំងអស់នេះ មានន័យថាគ្រួសារមានអារម្មណ៍ថាត្រូវតែឱ្យសមាជិកគ្រួសារគ្រប់គ្នាធ្វើការដើម្បីរកចំណូលឱ្យបានច្រើន ។ ទោះបីជាមានការអនុវត្តលក្ខខណ្ឌទាំងនេះទៅលើកម្មករក្ដី ម្ចាស់សិប្បកម្មមួយកន្លែងបានបដិសេធអំពីតួនាទី និងទំនួលខុសត្រូវរបស់ពួកគេទាក់ទងនឹងពលកម្មកុមារ ដោយអះអាងថា ពួកគេមិនបានជួលកុមារឱ្យធ្វើការងារផ្លូវការនោះទេ ហើយបែរជាបន្ទោសឳពុកម្ដាយក្មេងទៅវិញ ។ ខណៈដែលម្ចាស់សិប្បកម្មជារឿយៗណែនាំ កម្មករមិនឱ្យកូនអាយុក្រោម ១៥ឆ្នាំធ្វើការ ឬលេងនៅក្បែរបរិវេណការងារ ការណែនាំទាំងនេះមិនត្រូវបានអនុវត្តយ៉ាងហ្មត់ចត់ឡើយ ។



---

[៣៦] អាយុត្រូវបានរាយការណ៍ប្រាប់ដោយក្មេង ឬគ្រួសាររបស់ក្មេង

[៣៧] ប្រការ ៦ នៃប្រកាសលេខ ៣០៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ស្ដីពីលក្ខខណ្ឌការងារ និងរស់នៅ នៅក្នុងសិប្បកម្មផលិតឥដ្ឋ

[៣៨] ការងារគ្រោះថ្នាក់ខ្លាំងដែលត្រូវបានហាមឃាត់រួមមាន "ការងារនៅក្បែរឡដុត ឬចង្ក្រាន ដែលជាផ្នែកមួយនៃខ្សែសង្វាក់ផលិតកម្មឥដ្ឋ" និង "ការងារដែលត្រូវធ្វើនៅក្រោមកំដៅក្ដៅខ្លាំងហួសហេតុ..." សូមមើលកថាខណ្ឌទី ២(២៥) និង ២(៣៨) នៃប្រកាសលេខ ១០៦ ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០០៤ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្ដីពីការហាមឃាត់ពលកម្មកុមារដែលមានលក្ខណៈគ្រោះថ្នាក់ខ្លាំង

[៣៩] ការងារពេលយប់ដោយកុមារអាយុក្រោម ១៨ ឆ្នាំ ត្រូវបានហាមឃាត់ សូមមើលមាត្រា ១៧៥ ដល់ ១៧៦ នៃច្បាប់ការងារ

[៤០] ដូចខាងលើ



## គ្រឿងម៉ាស៊ីនប្រកបដោយគ្រោះថ្នាក់ត្រូវបានបញ្ជាដោយកុមារ

អង្គការលីកាដូ បានសង្កេតឃើញ ផល* ដែលជាក្មេងប្រុសអាយុ ១៦ឆ្នាំ និងកុមារផ្សេងទៀតក្នុងគ្រួសាររបស់គាត់ផលិតឥដ្ឋ ។ ដំបូងផលកាត់ និងបោះដីឥដ្ឋចូលក្នុងម៉ាស៊ីនផលិតឥដ្ឋដែលបញ្ជាដោយដៃ ។ ម៉ាស៊ីនបែបនេះប្រកបដោយគ្រោះថ្នាក់យ៉ាងខ្លាំង និងអាចបង្កឱ្យបាត់បង់ដៃជើង ។ នៅពេលដែលដីឥដ្ឋស្ថិតជាប់ក្នុងម៉ាស៊ីន ផលឈរលើផ្ទៃខាងលើនៃម៉ាស៊ីនដែលសើមនិងកខ្វក់ ហើយយកជើងទទេររបស់គាត់រុញដីឥដ្ឋឱ្យចូលក្នុងចន្លោះដែក ដែលគ្មានគម្រប និងកំពុងវិល ។ បន្ទាប់មក មុនី ដែលជាក្មេងស្រីអាយុ ១៦ឆ្នាំ កាត់តម្រឹមឥដ្ឋដែលចេញពីម៉ាស៊ីនថ្មីៗ ជាមួយនឹងឧបករណ៍សរសៃលួស រួចប្រគល់ឱ្យភីណាដែលជាក្មេងស្រីអាយុ ១៥ឆ្នាំ និងជាអ្នកលើកជញ្ជូនឥដ្ឋដាក់លើរទេះ ។ តាមគេប្រាប់មក ដារ៉ា និងធារី ដែលមានអាយុ ៩ឆ្នាំ និង១៣ឆ្នាំ ជួយរុញរទេះទាំងនេះ។ ស្របពេលជាមួយគ្នា កុមារទាំងពីរនាក់នេះ ត្រូវបានគេឃើញថាធ្វើការងាររតម្រៀបឥដ្ឋជាច្រើនជួរវែងៗដើម្បីហាល និងចាំគ្របផ្ទាំងសំពត់បាំងការពារទឹកភ្លៀង ។ គ្រួសាររបស់ពួកគេបានជាប់ជំពាក់បំណុលឧស្សាហកម្មឥដ្ឋអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ ហើយបច្ចុប្បន្ននេះនៅជាប់ជំពាក់ម្ចាស់សិប្បកម្មរាប់ពាន់ដុល្លារ ។

*ឈ្មោះទាំងអស់ត្រូវបានប្តូរ

## ការធ្វើការនៅសិប្បកម្មផលិតឥដ្ឋដោយកុមារអាយុក្រោម ១៨ឆ្នាំ គឺជាការបំពានលើច្បាប់អន្តរជាតិ

កម្ពុជាបានផ្តល់សច្ចាប័ណ្ណលើអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដោយប្តេជ្ញាហាមឃាត់ និងលុបបំបាត់ជាបន្ទាន់នូវទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មដោយកុមារដែលមានអាយុក្រោម ១៨ឆ្នាំ ។[៤១] ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ រួមមាន "គ្រប់ទម្រង់ទាំងអស់នៃទាសភាព ឬការអនុវត្តស្រដៀងនឹងទាសភាព ដូចជា [...] ទាសភាពបំណុល" ក៏ដូចជាការងារទាំងឡាយណាដែលអាចប៉ះពាល់ដល់សុខភាព ឬសុវត្ថិភាពរបស់កុមារ ។[៤២]

កុមារនៅតាមសិប្បកម្មផលិតឥដ្ឋនៅកម្ពុជា ច្រើនតែធ្វើការពាក់ព័ន្ធនឹងទាសភាពបំណុលរបស់ឪពុកម្តាយ ហើយការងាររបស់ពួកគេរួមចំណែកដល់ផលិតកម្មរបស់ឪពុកម្តាយដែលទទួលបានប្រាក់ឈ្នួលទាប ។ ការងារនៅសិប្បកម្មផលិតឥដ្ឋក៏ប្រកបដោយគ្រោះថ្នាក់ដល់សុខភាព និងសុវត្ថិភាពកុមារផងដែរ ។ ដូចបានកំណត់ដោយអង្គការពលកម្មអន្តរជាតិ ការងារប្រកបដោយគ្រោះថ្នាក់ រួមមានការងារបញ្ជាគ្រឿងម៉ាស៊ីន និងឧបករណ៍ប្រកបដោយគ្រោះថ្នាក់ ការលីសែងធ្ងន់ បរិយាកាសមិនមានផាសុកភាពដោយសារសារធាតុបង្កឱ្យមានគ្រោះថ្នាក់ និងកម្តៅហួសកម្រិត និងលក្ខខណ្ឌការងារពិបាកដូចជាការងារច្រើនម៉ោង ការងារពេលយប់ និងការបង្ខាំងមិនសមហេតុផលឱ្យនៅកន្លែងការងាររបស់និយោជក ។[៤៣]

ស្រដៀងគ្នានេះដែរ ច្បាប់ការងាររបស់កម្ពុជា ហាមកុមារអាយុក្រោម ១៨ឆ្នាំ ធ្វើការងារប្រកបដោយគ្រោះថ្នាក់ដល់សុខភាព ឬសុវត្ថិភាពរបស់ក្មេង ។[៤៤] ប្រកាសឆ្នាំ២០០៤ ស្តីពីការហាមឃាត់កុមារធ្វើការនៅកន្លែងការងារ ប្រកបដោយគ្រោះថ្នាក់ ចេញដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា[៤៥] កំណត់គ្រប់ការងារក្បែរឡឥដ្ឋដែលជាផ្នែកមួយនៃដំណើរការនៃផលិតកម្មឥដ្ឋគឺប្រកបដោយគ្រោះថ្នាក់ ក៏ដូចជាប្រភេទការងារមួយចំនួនផ្សេងទៀតពាក់ព័ន្ធនឹងដំណើរការផលិតឥដ្ឋដូចជាការលើកដាក់ លីសែង យួរកាន់ និងចលនារបស់ធ្ងន់ៗ ការងារពាក់ព័ន្ធដែលប្រឈមនឹងចំហេះផ្សែង ធូលី ឧស្ម័ន និងសារធាតុផ្សេងៗ ដែលអាចប៉ះពាល់ដល់ផ្លូវដង្ហើមរបស់មនុស្ស និងការងារស្ថិតក្រោមលក្ខខណ្ឌក្តៅហួសកម្រិត ។[៤៦] ប្រកាសឆ្នាំ២០០៧ ស្តីពីលក្ខខណ្ឌការងារ និងជីវភាពរស់នៅក្នុងសហគ្រាសឡឥដ្ឋ ចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ហាមជាពិសេសកុមារអាយុក្រោម ១៥ ឆ្នាំ ធ្វើការងារនៅតាមសិប្បកម្មផលិតឥដ្ឋរួមទាំងការជួយឪពុកម្តាយផងដែរ ។[៤៧] ក៏ប៉ុន្តែច្បាប់នៅកម្ពុជាអនុញ្ញាតឱ្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាផ្តល់នូវករណីលើកលែងអាស្រ័យតាមប្រភេទករណី ដោយអនុញ្ញាតឱ្យក្មេងអាយុចាប់ពី ១៦ឆ្នាំ ឡើងទៅធ្វើការងារគ្រោះថ្នាក់បាន តែក្នុងករណីដែលកុមារទាំងនោះមានការបណ្តុះបណ្តាលបានត្រឹមត្រូវ មិនត្រូវធ្វើការពីម៉ោង ១០ យប់ ដល់ម៉ោង ៥ ព្រឹក ហើយនិយោជកត្រូវប្រឹក្សាជាមួយគណកម្មាធិកាប្រឹក្សាយោបល់ការងារជាមុនសិន ។[៤៨] អត្ថិភាពនៃករណីលើកលែងសម្រាប់អនុញ្ញាតឱ្យមានពលកម្មកុមារលើការងារគ្រោះថ្នាក់ក្នុងសិប្បកម្មឡឥដ្ឋនេះ គឺពោរពេញដោយបញ្ហា ។ ដោយពិចារណាទៅលើករណីដែលម្ចាស់សិប្បកម្មឡឥដ្ឋមួយចំនួន បដិសេធជាផ្លូវការ ថាមិនទទួលយកកុមារធ្វើការងារនោះទេ វានឹងបង្ករជាសំនួរថាតើករណីលើកលែងខាងលើនេះ អាចនឹងត្រូវបានប្រើប្រាស់ឬទេ ។ លើសពីនេះ មិនមានករណីលើកលែងតាមផ្លូវច្បាប់សម្រាប់កុមារធ្វើការងារ ជាផ្លូវការ នៅក្រោមរូបភាពជាការធ្វើការងារដោះបំណុល ឬទាសភាពសម័យទំនើប ដែលកំពុងបន្តកើតមានឡើងនៅក្នុងវិស័យសិប្បកម្មឡឥដ្ឋនៅកម្ពុជានោះទេ ។

[៤៣] មាត្រា ៣(ក) ៣(ឃ) និង៣(ង) នៃអនុសាសន៍របស់អង្គការពលកម្មអន្តរជាតិស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ឆ្នាំ១៩៩៩ (លេខ ១៩០)
[៤៤] មាត្រា ១៧៧(២) នៃច្បាប់ស្តីពីការងារ
[៤៥] ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវបានប្តូរទៅជាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៅឆ្នាំ២០០៦
[៤៦] ប្រកាសលេខ ១០៦ ចុះថ្ងៃទី ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៤ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ស្តីពីការហាមឃាត់កុមារធ្វើការនៅកន្លែងការងារ ប្រកបដោយគ្រោះថ្នាក់
[៤៧] មាត្រា ៦ នៃប្រកាសលេខ ៣០៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីលក្ខខណ្ឌការងារ និងជីវភាពរស់នៅក្នុងសហគ្រាសឡឥដ្ឋ
[៤៨] កថាខណ្ឌទី៣ នៃប្រកាសលេខ ១០៦ ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០០៤ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការហាមឃាត់ពលកម្មកុមារក្នុងទម្រង់គ្រោះថ្នាក់

វត្តមានកុមារក្មេងៗដែលមិនធ្វើការក៏មានជាទូទៅនៅក្នុងបរិវេណសិប្បកម្មផលិតឥដ្ឋ និងទីតាំងការងារប្រកបដោយគ្រោះថ្នាក់ផងដែរ ។ ផ្ទះស្នាក់នៅរបស់កម្មករខ្លះមានចម្ងាយតែប៉ុន្មានម៉ែត្រពីបរិវេណខ្សែសង្វាក់ផលិតកម្មប៉ុណ្ណោះ ដោយគ្មានការរៀបចំបែងចែកឱ្យដាច់ពីគ្នា ។ កុមារត្រូវបានសង្កេតឃើញថាចូលក្នុងបរិវេណខ្សែសង្វាក់ផលិតកម្ម ជួនកាលក្បាលរបស់ពួកគេនៅកៀកជិតម៉ាស៊ីនដែលកំពុងដំណើរការ ឡើងលេងលើឡឥដ្ឋដែលនៅទំនេរ គេងក្នុងអង្រឹងដែលចងជាប់ទៅនឹងឡឥដ្ឋ និងអង្គុយលើផ្នែកខាងក្រៅនៃម៉ាស៊ីនជីកដីដែលកំពុងដំណើរការ ។

គ្រួសារជាច្រើនបានរាយការណ៍ថាកុមារមួយចំនួនមិនធ្លាប់បានចូលសាលារៀន ឬក៏ឈប់រៀននៅត្រឹមបឋមសិក្សា ។ នេះបើតាមការរាយការណ៍ គឺដោយសារតម្លៃពាក់ព័ន្ធនឹងការសិក្សា ឬទីកន្លែងរស់នៅមិនចិតថេរ ដែលបង្កដោយការផ្លាស់ទីពីសិប្បកម្មផលិតឥដ្ឋមួយទៅសិប្បកម្មផលិតឥដ្ឋមួយទៀត ។ កម្មករភាគច្រើនបានរាយការណ៍ថាកុមារដែលទៅសាលារៀន គឺរៀននៅបឋមសិក្សា និងមានតែមួយចំនួនតូចប៉ុណ្ណោះដែលកំពុងរៀននៅវិទ្យាល័យ ។

បន្ទាប់ពីរៀបការរួច កូនរបស់កម្មករដែលបានធំពេញវ័យនៅសិប្បកម្មផលិតឥដ្ឋ ច្រើនតែបានផ្លាស់ទីទៅរស់នៅ និងធ្វើការនៅសិប្បកម្មផ្សេងទៀត ដែលពួកគេបានយកកម្ចីផ្ទាល់ខ្លួន ។ កម្មករម្នាក់បានពន្យល់ប្រាប់ថាកូន ដែលពេញវ័យទាំងប្រាំពីររបស់ពួកគេឥឡូវនេះមានជំពាក់បំណុលសិប្បកម្មដ៏ទៃទៀត ។

**គ្រួសារជាច្រើនបានរាយការណ៍ថាកុមារមួយចំនួនមិនធ្លាប់បានចូលសាលារៀន ឬក៏ឈប់រៀននៅត្រឹមបឋមសិក្សា ។**



## ការងារធ្ងន់ និងសុខភាពមិនល្អ

*បូរាណ* ចាប់ផ្តើមរុញឥដ្ឋពីម៉ាស៊ីនយកទៅហាលថ្ងៃ តាំងពីអាយុ ១៥ឆ្នាំ ។ ឥឡូវនេះ វ័យ ១៧ឆ្នាំ គាត់ធ្វើការឱ្យអ្នកបើករថយន្តដឹកជញ្ជូន ដោយជញ្ជូនឥដ្ឋចុះនិងឡើងពីរថយន្ត ។ រថយន្តនីមួយៗ ផ្ទុកឥដ្ឋចំនួន ១០ ០០០ដុំ ហើយបូរាណទទួលបានប្រាក់ឈ្នួលសរុប ២០ ០០០ រៀល (ប្រហែល ៥ ដុល្លារ) សម្រាប់ការលើកជញ្ជូនចុះឡើងក្នុងមួយរថយន្ត ។ បូរាណមានបញ្ហាកង្វះគ្រាប់ឈាមក្រហមច្រើនតែខ្សោយកម្លាំង និងតែងតែឈឺក្បាល និងឈឺក្រពះ ។ តម្លៃអាហារថ្ងៃ គួបផ្សំជាមួយនឹងសុខភាពមិនល្អ មានន័យថាគាត់មិនសូវបរិភោគអាហារបានទៀងទាត់ ទោះបីជាការងារត្រូវលីសែងធ្ងន់ក្តី ហើយគាត់ពឹងផ្អែកលើគ្រឿងភេសជ្ជៈផ្អែមៗ ដើម្បីផ្តល់ជាថាមពល ។*

** ឈ្មោះត្រូវបានប្តូរ*



## ការចុះធ្វើអធិការកិច្ចពុំមានសង្គតិភាព និងប្រសិទ្ធភាព

មន្ត្រីអធិការកិច្ចការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានភារកិច្ចចុះពិនិត្យកន្លែងការងារ និងពង្រឹងការអនុវត្តច្បាប់ការងារទាក់ទងនឹងសុខភាព លក្ខខណ្ឌការងារ និងសន្តិសុខ ។[៤៩] ក៏ប៉ុន្តែការចុះធ្វើអធិការកិច្ចនៅតាមសិប្បកម្មផលិតឥដ្ឋត្រូវបានគេសង្កេតឃើញថាមិនមានលក្ខណៈស៊ីចង្វាក់គ្នា និងគ្មានប្រសិទ្ធភាព ។ ក្រសួងការងារសហរដ្ឋអាមេរិកបានរាយការណ៍ថាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរបស់កម្ពុជា បានចុះពិនិត្យទីតាំងសិប្បកម្មផលិតឥដ្ឋចំនួន ៦២ កន្លែងនៅឆ្នាំ ២០២០ ប៉ុន្តែច្រើនតែផ្តល់ដំណឹងជាមុនដល់ម្ចាស់សិប្បកម្ម ដែលនេះជាការទុកឱកាសឱ្យម្ចាស់សិប្បកម្មលាក់បាំងភស្តុតាងនៃទាសភាពបំណុល និងពលកម្មកុមារ ។[៥០]

កម្មករមួយចំនួន បានប្រាប់អង្គការលីកាដូថាពួកគេមិនធ្លាប់ឃើញមានការចុះធ្វើអធិការកិច្ចទាល់តែសោះ ឬក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនេះ ។ កម្មករខ្លះទៀតធ្លាប់ឃើញមន្ត្រីនគរបាល ឬអាជ្ញាធរពាក់ឯកសណ្ឋានផ្សេងទៀតចុះមកសិប្បកម្មក្នុងរយៈពេលមួយឆ្នាំកន្លងមកនេះ ។ ពួកគេបានរាយការណ៍ថាមន្ត្រីនគរបាលខ្លះបានប្រកាសថាកុមារមិនត្រូវបានអនុញ្ញាតឱ្យធ្វើការ ឬទៅក្បែរម៉ាស៊ីនផលិតឥដ្ឋ ហើយឪពុកម្តាយក្មេងមិនត្រូវឱ្យកូនដើរតាមពួកគេខណៈដែលកំពុងធ្វើការឡើយ ។ កម្មករម្នាក់បាននិយាយថាអាជ្ញាធរស្លៀកឯកសណ្ឋានបានមកជួបជាមួយម្ចាស់សិប្បកម្ម និងពិនិត្យមើលម៉ាស៊ីន ។ កម្មករបន្តធ្វើការងាររបស់ពួកគេអំឡុងពេលនៃការចុះពិនិត្យនេះ ហើយគាត់មិនបានដឹងថាអាជ្ញាធរទាំងនេះបាននិយាយផ្ទាល់ជាមួយកម្មករណាមួយឡើយ ។ កម្មករម្នាក់ផ្សេងទៀតបានរាយការណ៍ថាអាជ្ញាធរបាននិយាយជាមួយម្ចាស់សិប្បកម្ម និងកម្មករតែម្នាក់ប៉ុណ្ណោះ ។ ក្រោយពីការចុះពិនិត្យមើលលើសិប្បកម្មរបស់អាជ្ញាធរទាំងអស់នេះ ម្ចាស់សិប្បកម្មជួនកាលបានណែនាំកម្មករកុំឱ្យកូនធ្វើការ ។

ទោះជាយ៉ាងនេះក្តី ការចុះធ្វើអធិការកិច្ចការងារទាំងនេះមិនបាននាំឱ្យមានភាពប្រសើរឡើងជាប្រព័ន្ធនៅក្នុងសិប្បកម្មផលិតឥដ្ឋនោះទេ ដោយសារគ្មានការដាក់ទោសទណ្ឌទៅលើម្ចាស់សិប្បកម្មដែលប្រើពលកម្មដើម្បីដោះបំណុល ឬពលកម្មកុមារនៅក្នុងសិប្បកម្មរបស់ពួកគេ ។

**កម្មករមួយចំនួនបានប្រាប់អង្គការលីកាដូថាពួកគេមិនធ្លាប់ឃើញមានការចុះធ្វើអធិការកិច្ចទាល់តែសោះ ឬក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនេះ ។**

[៤៩] មាត្រា ២៣៣ នៃច្បាប់ស្តីពីការងារ

[៥០] "របាយការណ៍ស្តីពីការជួញដូរមនុស្សឆ្នាំ២០២១៖ នៅកម្ពុជា" ក្រសួងការបរទេសសហរដ្ឋអាមេរិក ឆ្នាំ២០២១ អាចរកបាននៅ https://www.state.gov/reports/2021-trafficking-in-persons-report/cambodia/



## ឡតដ្ឋដុតដោយកម្ទេចសំណល់ក្រណាត់

សំណល់ពីឧស្សាហកម្មកាត់ដេរ ត្រូវបានដុតជាទូទៅដើម្បីកំដៅឡតដ្ឋ ទោះជាវាធ្វើឱ្យមនុស្សប្រឈមនឹងសារធាតុពុល និងបង្កផលប៉ះពាល់អវិជ្ជមានដល់សុខភាព និងបរិស្ថានក្តី ។[៥១] សិប្បកម្មផលិតឥដ្ឋជាច្រើន ច្រើនតែដុតអុស[៥២] លាយជាមួយសំណល់ពីឧស្សាហកម្មនេះដែលរួមមានកម្ទេចក្រណាត់ ប្លាស្ទិក ជ័រ និងវត្ថុផ្សេងៗ ដើម្បីកាត់បន្ថយចំណាយលើការដុតកំដៅឡតដ្ឋ ។ ពីមុនកម្មករធ្លាប់រាយការណ៍អំពីផលប៉ះពាល់រួមមានការក្អក ផ្តាសាយ គ្រុនក្តៅ ឈាមច្រមុះ និងរលាកស្បែកជាដើម ។[៥៣] សហគមន៍ដែលនៅក្បែរក៏បានរាយការណ៍ថាការអនុវត្តនេះធ្វើឱ្យខូចខាតដំណាំ និងដីចំការរបស់ពួកគេ ។[៥៤]

អង្គការលីកាដូ បានកត់សម្គាល់ឃើញមានកម្ទេចសំណល់ក្រណាត់នៅសិប្បកម្មផលិតឥដ្ឋដែលដំណើរការ ចំនួនប្រាំទីតាំង និងសិប្បកម្មដែលបានបិទអាជីវកម្មចំនួនពីរទីតាំង ។ កម្មករមួយចំនួនបានរាយការណ៍ថាការដុតកម្ទេចក្រណាត់ បានធ្វើឱ្យពួកគេឈឺក្បាល និងមានបញ្ហាផ្លូវដង្ហើម ។ កម្មករម្នាក់ទៀតបានរាយការណ៍ថាការដុតនេះ ធ្វើឱ្យគាត់មិនសូវស្រួលខ្លួនខ្លាំងជាពិសេសនៅពេលគាត់មានផ្ទៃពោះ ។ សំណល់ក្រណាត់ដែលរក្សាទុកនៅសិប្បកម្មផលិតឥដ្ឋមួយកន្លែង បានបង្កឱ្យមានអគ្គិភ័យមួយឆេះយ៉ាងខ្លាំង និងគម្រាមកំហែងដល់សុវត្ថិភាពកម្មករ ។

**កម្មករមួយចំនួនបានរាយការណ៍ថាការដុតកម្ទេចក្រណាត់បានធ្វើឱ្យពួកគេ ឈឺក្បាល និង មានបញ្ហាផ្លូវដង្ហើម ។**

[៥១] Brickell et al, "ដុំឥដ្ឋលោហិតៈ រឿងរ៉ាវដែលគេមិនដែលប្រាប់អំពីទាសភាពសម័យទំនើប និងការប្រែប្រួលអាកាសធាតុនៅកម្ពុជា" ទំព័រទី ៣៨-៣៩។

[៥២] អង្គការលីកាដូមិនបានធ្វើការស៊ើបអង្កេតប្រភពឈើដែលប្រើសម្រាប់ដុះក្នុងឡតដ្ឋនោះទេ ប៉ុន្តែអុសក៏ហាក់ជាប្រភពឥន្ទនៈដែលមិនមានចីរភាពផងដែរ បើគិតពីកម្រិតប្រេវ៉ាឡង់នៃការកាប់ឈើខុសច្បាប់ និងគ្មាននិរន្តរភាពនៅកម្ពុជា។ សូមមើលឧទាហរណ៍ដូចជា Hannah Guy "របាយការណ៍ផែនទីបង្ហាញលំហូរសំណល់៖ ផ្លូវលំហូរពីអ្នកផ្គត់ផ្គង់សំខាន់ៗទៅទីចាក់សំណល់" របស់ FABRIC និង GIZ ទំព័រទី២៩ ឆ្នាំ២០២១ អាចរកបាននៅ https://asiagarmenthub.net/resources/2021/waste-streams-mapping_cambodia-1.pdf

[៥៣] Brickell et al, "ដុំឥដ្ឋលោហិតៈ រឿងរ៉ាវដែលគេមិនដែលប្រាប់អំពីទាសភាពសម័យទំនើប និងការប្រែប្រួលអាកាសធាតុនៅកម្ពុជា" ទំព័រទី ៣៨-៣៩។ Kasztelan និង Quashie-Idun "ត្រូវបានលាតត្រដាង៖ សំណល់ក្រណាត់របស់ណៃខ៍ ខ្លាកស៍ និងម៉ាកល្បីនាំមុខដទៃទៀតត្រូវបានដុតបញ្ឆេះឡតដ្ឋដែលមានជាតិពុលនៅកម្ពុជា" សារព័ត៌មាន Unearthed (អង្គការ Greenpeace ចក្រភពអង់គ្លេស) ថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២

[៥៤] Guy "របាយការណ៍ផែនទីបង្ហាញលំហូរសំណល់៖ ផ្លូវលំហូរពីអ្នកផ្គត់ផ្គង់សំខាន់ៗទៅទីចាក់សំណល់" របស់ FABRIC និង GIZ ទំព័រទី២៩ ឆ្នាំ២០២១

## កុមារថប់ដង្ហើមដោយសារផ្សែងមានជាតិពុល

បូសុគន្ធ* បានធ្វើការនៅសិប្បកម្មផលិតឥដ្ឋមួយកន្លែងដែលដុតតែកម្ទេចក្រណាត់ប៉ុណ្ណោះ មុនពេលសិប្បកម្មនេះត្រូវបានបិទ ។ ឡឥដ្ឋត្រូវបានដុតដោយកម្ទេចក្រណាត់រយៈពេល ២៤ ម៉ោងក្នុងមួយថ្ងៃ និងក្នុងរយៈពេលជាច្រើនសប្តាហ៍ក្នុងមួយលើក ។ ការដុតនិងរក្សាភ្លើងឡឥដ្ឋមួយត្រូវការកម្ទេចក្រណាត់ចំនួន ២០ រថយន្ត ។ សុគន្ធ ទទួលខុសត្រូវរក្សាភ្លើងឡឥដ្ឋ ហើយគាត់ក៏រស់នៅក្នុងសិប្បកម្មផ្ទាល់ជាមួយគ្រួសារផងដែរ ។

គ្រួសាររបស់សុគន្ធតែងតែក្រោកជារៀងរាល់ថ្ងៃជាមួយនឹងធូលីពណ៌ខ្មៅនៅក្បែររន្ធច្រមុះ ដោយសារស្រូបផ្សែងចូលតាមដង្ហើម ។ កុមារមួយចំនួនដែលមានអាយុក្បែរ ៦ ឆ្នាំទៅ ៨ ឆ្នាំ ត្រូវការការព្យាបាលបញ្ហាផ្លូវដង្ហើមជាច្រើនសារដែលរួមមានជំងឺហឺត ការពិបាកដកដង្ហើម និងក្អក ។ ម្ចាស់សិប្បកម្មមិនបានផ្តល់ជំនួយអ្វីសោះ ដើម្បីដោះស្រាយបញ្ហាប្រកបដោយគ្រោះថ្នាក់ទាំងនេះ ។ សុគន្ធបានទិញម៉ាស និងស្រោមដៃផ្ទាល់ខ្លួនសម្រាប់ពាក់ដើម្បីផ្តល់ជាការការពារបន្តិចបន្តួច នៅពេលបំពេញការងារ ។

ចាប់តាំងពីសិប្បកម្មផលិតឥដ្ឋបានបិទអាជីវកម្មមក សុគន្ធរាយការណ៍ថាសុខភាពរបស់កុមារបានប្រសើរឡើងច្រើន ដោយសារពួកគេលែងប្រឈមនឹងផ្សែងដែលមានសារធាតុបង្កគ្រោះថ្នាក់ ។

* ឈ្មោះត្រូវបានប្តូរ

**អង្គការលីកាដូ បានសម្គាល់ឃើញស្លាក ឬម៉ាករបស់ក្រុមហ៊ុនសំលៀកបំពាក់អន្តរជាតិចំនួន ១៩ ពីកម្ទេចសំណល់ក្រណាត់នៅសិប្បកម្មផលិតឥដ្ឋ ។[៥៥] ម៉ាកទាំងនេះ រួមមាន៖**

អេឌីដាស

រីបុក

លូលូឡេម៉ុន

អាន់ឌើ អាមើ

ហ្គាប អ៊ូលណាវី អេន អាសឡេតា (កាន់កាប់ដោយ ហ្គាប អ៊ិនខ៍)

ព្រីម៉ាក

លូពីលូ (កាន់កាប់ដោយលីឌល៍ ស្ទីហ្វតុង & ខូ)

នូ បោនឌើរី អេន ហ្គូច (កាន់កាប់ដោយ វ៉លម៉ាត)

ក្រុប អេន ស៊ីនសេ (កាន់កាប់ដោយ អេលភីភី)

ស៊ី&អេ

ខាវ៉ូបូន

ខៀប៊ី

ស្វេតធី បេតធី

ធីឡេ អិនដួររេបបលស៍

វីនើស ហ្វេសិន

ឌីសនី

អង្គការ លីកាដូ បានសរសេរលិខិតទៅកាន់ម៉ាកសម្លៀកបំពាក់នីមួយៗដែលពាក់ព័ន្ធ ឬក្រុមហ៊ុនមេរបស់ពួកគេ កាលពីខែកញ្ញា ឆ្នាំ២០២៣ ដើម្បីស្នើសុំឲ្យអ្នកទាំងនោះបញ្ឈប់ ការពារ និងដោះស្រាយផលប៉ះពាល់អវិជ្ជមានទាំងនេះ ។ ក្រុមហ៊ុនម៉ាកសម្លៀកបំពាក់ ឬក្រុមហ៊ុនមេទាំងនេះ ត្រូវបានទុកពេលវេលា ដើម្បីឆ្លើយតបទៅនឹងសំណើខាងលើនេះ ហើយអង្គការ លីកាដូ បានប្រាប់ក្រុមហ៊ុនទាំងនោះថា ការឆ្លើយតបរបស់ពួកគេ នឹងត្រូវផ្សព្វផ្សាយជាសាធារណៈ ដែលជាផ្នែកមួយនៃរបាយការណ៍នេះ ប្រសិនបើ លីកាដូ ទទួលបានការឆ្លើយតបមុនពេលការចេញផ្សាយរបាយការណ៍ ។ ក្រុមហ៊ុនចំនួនប្រាំ បានឆ្លើយតបនៅក្នុងរយៈពេលដែលបានផ្តល់ឱ្យ។ ក្រុមហ៊ុនដែលឆ្លើយតបទាំងអស់ សុទ្ធតែទទួលបានលិខិតរបស់អង្គការ លីកាដូ ហើយមានមួយចំនួនក្នុងចំណោមក្រុមហ៊ុនទាំងនោះ បានបញ្ជាក់ពីផែនការសកម្មភាពដូចជា៖

- អេឌីដាស (Adidas) បានបង្ហាញថាខ្លួនបានចាប់ផ្តើមស៊ើបអង្កេតករណីនេះហើយ
- ធីឡេ អិនដួររេបបលស៍ (Tilley Endurables) បាននិយាយថាពួកគេកំពុងចាត់វិធានការការពារផ្សេងទៀត
- លីឌល៍ ស្ទីហ្វតុង & ខូ (Lidl Stiftung & Co) ស្នើសុំជួបជាមួយអង្គការ លីកាដូ
- អិលភីភី (LPP) ស្នើសុំពេលវេលាបន្ថែមដើម្បីឆ្លើយតប ហើយ
- លូលូឡេម៉ុន អាតស៍ឡេធិកា (lululemon athletica) ទទួលបានលិខិតរបស់អង្គការ លីកាដូ

អង្គការ លីកាដូ នឹងផ្សព្វផ្សាយការធ្វើបច្ចុប្បន្នភាពនៅលើគេហទំព័ររបស់ខ្លួន នៅពេលទទួលបានការឆ្លើយតបបន្ថែមណាមួយទៀតក្រុមហ៊ុនម៉ាកសម្លៀកបំពាក់ ។[៥៦]

[៥៥] សូមមើល "សំណល់កម្ទេចក្រណាត់របស់ម៉ាកសម្លៀកបំពាក់អន្តរជាតិត្រូវបានដុតនៅតាមសិប្បកម្មផលិតឥដ្ឋនៅកម្ពុជា ហើយមានតែក្រុមហ៊ុនមួយចំនួនតូចប៉ុណ្ណោះដែលប្តេជ្ញាធ្វើការស៊ើបអង្កេតលើរឿងនេះ" លីកាដូ វិច្ឆិកា ២០២៣ តាមរយៈ https://www.licadho-cambodia.org/album/view_photo.php?cat=107&khmer

[៥៦] ដូចខាងលើ

អ្នកសារព័ត៌មាន និងអ្នកសិក្សាស្រាវជ្រាវពីមុនៗក៏បានសម្គាល់ឃើញនូវសំណល់តាមសិប្បកម្មផលិតឥដ្ឋកម្ពុជាដែលជារបស់ក្រុមហ៊ុនម៉ាក រួមមានណៃខ៍ វ៉ាហ្វ ឡូរិន ម៉ៃខើល ខស វីបុក និច ឌីសែល ខ្លាកស៍ ម៉ាកស៍អេនស្ពិនសើស៍ ហ្គាចអែតអេសដា ភូល&បែរ ចេគ្រូ វ៉លម៉ាត និងអូលណាវី ។[៥៧]

ចំនួនសមាមាត្រនៃសិប្បកម្មផលិតឥដ្ឋដែលដំណើរការ និងប្រើប្រាស់សំណល់ក្រណាត់ អាចមានការកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ ។ ការសិក្សាស្ទង់មតិឯករាជ្យថ្នាក់ជាតិមួយអំពីឧស្សាហកម្មផលិតឥដ្ឋដែលបានធ្វើឡើងនៅឆ្នាំ២០១៩ បានរកឃើញថា សិប្បកម្មផលិតឥដ្ឋ ២៣ ទីតាំង ក្នុងចំណោមសិប្បកម្មផលិតឥដ្ឋចំនួន ៤៦៥ កន្លែង បានប្រើប្រាស់សំណល់ឧស្សាហកម្មកាត់ដេរ ជាសម្ភារៈសម្រាប់ដុតបញ្ចេះឡឥដ្ឋ ។[៥៨] ការស៊ើបអង្កេតមួយរបស់សារព័ត៌មាន Unearthed នៃអង្គការហ្គ្រីនភីស (Greenpeace) បានរាយការណ៍ថាការប្រើប្រាស់សំណល់ឧស្សាហកម្មនេះបានកើនឡើងក្នុងឆ្នាំ២០២១ ស្របពេលដែលប្រាក់កម្រៃរបស់សិប្បកម្មផលិតឥដ្ឋបានថយចុះ ។[៥៩] ទោះបីជាវាមិនតំណាងឱ្យឧស្សាហកម្មទាំងមូលក្តី គួរកត់សម្គាល់ថាអង្គការលីកាដូ បានរកឃើញសំណល់ក្រណាត់នៅសិប្បកម្មផលិតឥដ្ឋចំនួនប្រាំពីរទីតាំង ក្នុងចំណោម ២០ ទីតាំងដែលបានសិក្សាក្នុងឆ្នាំនេះ ។

អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង ឆ្នាំ១៩៩៩ កំណត់ សំណល់ក្រណាត់ពីឧស្សាហកម្មកាត់ដេរថាជាសំណល់ប្រកបដោយគ្រោះថ្នាក់ និងចែងថាការដឹកជញ្ជូន និងទីតាំងចាក់ចោលសំណល់នេះត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន ។[៦០] មានតែក្រុមហ៊ុនមួយចំនួនតូចប៉ុណ្ណោះទទួលបានអាជ្ញាប័ណ្ណដឹកជញ្ជូន និងចាក់ចោលសំណល់នេះ ។ ថ្វីត្បិតយ៉ាងនេះក្តី មានឯកសារចងក្រងពីមុនបានបង្ហាញថាសំណល់ក្រណាត់ជាទូទៅត្រូវបានទិញទុកសម្រាប់លក់ដោយក្រុមឈ្មួញកណ្តាលដែលគ្មានអាជ្ញាប័ណ្ណមុននឹងសំណល់នេះទៅដល់ឡឥដ្ឋ ។[៦១]

ក្រសួងបរិស្ថាន មានតួនាទីធ្វើអធិការកិច្ច និងត្រួតពិនិត្យការគ្រប់គ្រងសំណល់ដែលមានសារធាតុបង្កគ្រោះថ្នាក់នេះ រួមទាំងការចុះពិនិត្យជាបន្ទាន់ទៅលើការបោះចោលសំណល់ប្រកបដោយគ្រោះថ្នាក់ដែលត្រូវបានគេរាយការណ៍ថាបង្កគ្រោះថ្នាក់ដល់សុខភាព ឬបរិស្ថាន ។[៦២]

ដូចគ្នាដែរ ក្រុមហ៊ុនសំលៀកបំពាក់ម៉ាកអន្តរជាតិ មិនបានដោះស្រាយបញ្ហាដែលបង្កឡើងដោយការដុតកំទេចសំណល់ផលិតផលរបស់ពួកគេនៅតាមសិប្បកម្មផលិតឥដ្ឋ បើទោះជាមានរបាយការណ៍ជាសាធារណៈបានចេញផ្សាយពីមុនៗ ទៅលើបញ្ហានេះហើយក៏ដោយ ហើយក្រុមហ៊ុនម៉ាកអន្តរជាតិជាច្រើនក៏ត្រូវបានគេទាក់ទង និងជូនដំណឹងអំពីបញ្ហានៃកាកសំណល់ផលិតផលរបស់ពួកគេត្រូវបានដុតក្នុងសិប្បកម្មឡឥដ្ឋក្តី ។[៦៣] ក្រុមហ៊ុនម៉ាកជាច្រើន ដែលត្រូវបានសម្គាល់ឃើញដោយអង្គការលីកាដូ មានគោលនយោបាយសាធារណៈ ឬការប្តេជ្ញាទៅលើបញ្ហាអាកាសធាតុ សិទ្ធិមនុស្ស និងការគ្រប់គ្រងសំណល់ ។ បើគិតពីទំហំនៃសំណល់ក្រណាត់របស់ក្រុមហ៊ុនម៉ាកដែលត្រូវបានគេរកឃើញនៅតាមសិប្បកម្មផលិតឥដ្ឋនោះ ក្រុមហ៊ុនសំលៀកបំពាក់ម៉ាកទាំងឡាយណាដែលទទួលបានផលិតផលរបស់ខ្លួនពីប្រទេសកម្ពុជាប្រឈមនឹងហានិភ័យដែលផលិតផល និងសំណល់ទាំងនេះបានជះផលប៉ះពាល់អាក្រក់ទៅលើពលករដែលធ្វើការដោះបំណុល កុមារ និងសហគមន៍នៅក្បែរដែលត្រូវប្រឈមនឹងផ្សែងពុល ។

**ចំនួនសមាមាត្រនៃសិប្បកម្មផលិតឥដ្ឋដែលដំណើរការ និងប្រើប្រាស់សំណល់ក្រណាត់ អាចមានការកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។**

**ក្រុមហ៊ុនសំលៀកបំពាក់ម៉ាកទាំងឡាយណាដែលទទួលបានផលិតផលរបស់ខ្លួនពីប្រទេសកម្ពុជា ប្រឈមនឹងហានិភ័យ ដែលផលិតផល និងសំណល់ទាំងនេះបានជះផលប៉ះពាល់អាក្រក់ទៅលើពលករដែលធ្វើការដោះបំណុល កុមារ និងសហគមន៍ ។**

[៥៧] Kasztelan និង Quashie-Idun "ត្រូវបានលាតត្រដាងៈ សំណល់ក្រណាត់របស់ណៃខ៍ ខ្លាកស៍ និងម៉ាកល្បីនាំមុខដទៃទៀតត្រូវបានដុតបញ្ចេះឡឥដ្ឋដែលមានជាតិពុលនៅកម្ពុជា" សារព័ត៌មាន Unearthed (អង្គការ Greenpeace ចក្រភពអង់គ្លេស) ថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២។ Brickell et al, "ដុំឥដ្ឋលោហិតៈ រឿងរ៉ាវដែលគេមិនដែលប្រាប់អំពីទាសភាពសម័យទំនើប និងការប្រែប្រួលអាកាសធាតុនៅកម្ពុជា"ទំព័រទី ៣៩។

[៥៨] សូមមើល "ទិដ្ឋភាពនៃការបោះចោលសំណល់ឧស្សាហកម្មកាត់ដេរអំឡុងពេលមានវិបត្តិជំងឺរីករាលដាល" គម្រោងស្រាវជ្រាវ Blood Bricks ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ អាចរកបាននៅ https://www.projectbloodbricks.org/blog/2020/5/26/discardscapes-of-preconsumer-garment-waste-in-cambodia

[៥៩] Kasztelan និង Quashie-Idun "ត្រូវបានលាតត្រដាងៈ សំណល់ក្រណាត់របស់ណៃខ៍ ខ្លាកស៍ និងម៉ាកល្បីនាំមុខដទៃទៀតត្រូវបានដុតបញ្ចេះឡឥដ្ឋដែលមានជាតិពុលនៅកម្ពុជា" សារព័ត៌មាន Unearthed (អង្គការ Greenpeace ចក្រភពអង់គ្លេស) ថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២ Kasztelan and Quashie-Idun

[៦០] មាត្រា ១៧ និងឧបសម្ព័ន្ធ កថាខណ្ឌទី ១ នៃអនុក្រឹត្យ លេខ ៣៦ ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសំណល់រឹង

[៦១] សម្រាប់ការពិភាក្សាថាតើសំណល់ក្រណាត់ទៅដល់សិប្បកម្មឡឥដ្ឋយ៉ាងណានោះ សូមមើល Guy, "របាយការណ៍ផែនទីបង្ហាញលំហូរសំណល់ៈ ផ្លូវលំហូរពីអ្នកផ្គត់ផ្គង់សំខាន់ៗទៅទីចាក់សំណល់"របស់ FABRIC និង GIZ។ Brickell et al, "ដុំឥដ្ឋលោហិតៈ រឿងរ៉ាវដែលគេមិនដែលប្រាប់អំពីទាសភាពសម័យទំនើប និងការប្រែប្រួលអាកាសធាតុនៅកម្ពុជា"ទំព័រទី ៣៩។ Kasztelan និង Quashie-Idun "ត្រូវបានលាតត្រដាងៈ សំណល់ក្រណាត់របស់ណៃខ៍ ខ្លាកស៍ និងម៉ាកល្បីនាំមុខដទៃទៀតត្រូវបានដុតបញ្ចេះឡឥដ្ឋដែលមានជាតិពុលនៅកម្ពុជា" សារព័ត៌មាន Unearthed (អង្គការ Greenpeace ចក្រភពអង់គ្លេស) ថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២

[៦២] មាត្រា ២២ និង២៦ នៃអនុក្រឹត្យលេខ ៣៦ ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសំណល់រឹង

[៦៣] Kasztelan និង Quashie-Idun "ត្រូវបានលាតត្រដាងៈ សំណល់ក្រណាត់របស់ណៃខ៍ ខ្លាកស៍ និងម៉ាកល្បីនាំមុខដទៃទៀតត្រូវបានដុតបញ្ចេះឡឥដ្ឋដែលមានជាតិពុលនៅកម្ពុជា" សារព័ត៌មាន Unearthed (អង្គការ Greenpeace ចក្រភពអង់គ្លេស) ថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២។ "កម្ពុជាៈ របាយការណ៍អំពីឧស្សាហកម្មឡឥដ្ឋបង្ហាញនូវការប្រើកម្ទេចក្រណាត់ឧស្សាហកម្មកាត់ដេរសម្រាប់ដុតឡឥដ្ឋ។ ក្រុមហ៊ុនមួយចំនួនប្តេជ្ញាធ្វើការស៊ើបអង្កេតនិងចាត់វិធានការ" របស់មជ្ឈមណ្ឌលធនធានធុរកិច្ច និងសិទ្ធិមនុស្ស ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ អាចរកបាននៅ https://www.business-humanrights.org/en/latest-news/cambodia-report-on-brick-industry-reveals-use-of-garment-fabrics-to-fuel-kilns-some-companies-commit-to-investigate-and-take-action/





## លក្ខខណ្ឌការងារ និងលទ្ធភាពទទួលបានការថែទាំសុខភាពនៅមិនទាន់គ្រប់គ្រាន់

កម្មករសិប្បកម្មផលិតឥដ្ឋនៅតែប្រឈមនឹងស្ថានភាពការងារ និងជីវភាពរស់នៅមិនល្អ និងខ្វះលទ្ធភាពទទួលបានការថែទាំសុខភាព ។ គ្មានកម្មករណាម្នាក់បានរាយការណ៍ថាខ្លួនមានកិច្ចសន្យាការងារឡើយ ។ ពួកគេមិនទទួលបានអត្ថប្រយោជន៍ផ្សេងៗដូចបានកំណត់ដោយច្បាប់ការងារកម្ពុជា ដូចជាប្រាក់ឈ្នួលបន្ថែមម៉ោង ថ្ងៃឈប់ដោយជំងឺ ថ្ងៃឈប់បុណ្យ និងការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល ឬការឈប់សម្រាកលំហែមាតុភាពនិងបិតុភាព ។ កម្មករដែលមានផ្ទៃពោះត្រូវបានគេរាយការណ៍ថាឈប់សម្រាកពីការងារតែមួយរយៈពេលខ្លីមុន និងក្រោយពេលសម្រាលកូន ។ ប្រកាសឆ្នាំ២០០៧ ចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តម្រូវឱ្យសិប្បកម្មផលិតឥដ្ឋផ្តល់ឧបករណ៍ការពារខ្លួន ធានាទីកន្លែងការងារមានសុវត្ថិភាព ផ្តល់សេវាសុខភាព ហើយធានាថាសីតុណ្ហភាពនៅកន្លែងការងារមិនឱ្យលើសពី ៣៧អង្សាសេ ។[៦៤] ទោះជាយ៉ាងនេះក្តី កាតព្វកិច្ចទាំងនេះភាគច្រើនត្រូវបានគេមើលរំលង ។

ផ្ទះស្នាក់នៅរបស់កម្មករត្រូវបានផ្តល់ឱ្យដោយម្ចាស់សិប្បកម្ម និងស្ថិតក្នុងទីតាំងសិប្បកម្មផ្ទាល់ ។ ក៏ប៉ុន្តែ មានតែម្ចាស់សិប្បកម្មមួយចំនួនប៉ុណ្ណោះដែលបង់ថ្លៃការប្រើប្រាស់ទឹក និងភ្លើងជំនួសកម្មករ ។ ផ្ទះច្រើនតែធ្វើពីឈើ និងសន្លឹកដែក ដែលកម្មករម្នាក់បានប្រាប់ថាគ្មានផាសុកភាពដោយសារតែក្តៅខ្លាំង ។ ផ្ទះភាគច្រើនមិនអាចបិទជាប់ធានាសុវត្ថិភាពដោយសារធ្វើពីរបស់អន់ និងងាយនឹងបាក់បែក ។ កម្មករស្រីម្នាក់បានប្រាប់ថាគាត់គ្មានអារម្មណ៍សុវត្ថិភាពនោះទេនៅពេលគាត់នៅផ្ទះម្នាក់ឯង ។

**គ្មានកម្មករណាម្នាក់បានរាយការណ៍ថាខ្លួនមានកិច្ចសន្យាការងារឡើយ ។**

[៦៤] មាត្រា ៣ និង៧ នៃប្រកាស លេខ ៣០៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីលក្ខខណ្ឌការងារ និងជីវភាពរស់នៅក្នុងសហគ្រាសឡឥដ្ឋ

ផ្ទះនីមួយៗនៅកៀកគ្នា ហើយគ្រួសារជាច្រើនជាទូទៅប្រើប្រាស់បន្ទប់ទឹករួម ។ កម្មករដដែល បានប្រាប់ថាបន្ទប់ទឹកនៅឆ្ងាយពីផ្ទះរបស់គាត់ ហើយគាត់មានអារម្មណ៍ថាគ្មានសុវត្ថិភាពនៅពេលដើរទៅបន្ទប់ទឹកតែឯងនៅពេលយប់ព្រលប់ ។ បន្ទប់ទឹកនៅក្នុងសិប្បកម្មគ្មានទឹក ហើយខ្លះទៀតគ្មានទ្វារ ដូច្នេះកម្មករត្រូវយួរទឹក និងយកក្រណាត់សម្រាប់បិទបាំង ។ កម្មករម្នាក់នៅសិប្បកម្មមួយផ្សេងទៀត បានរាយការណ៍ថាម្ចាស់សិប្បកម្មមិនអើពើពីសំណើធ្វើឱ្យមានភាពប្រសើរជាងនេះនៅក្នុងផ្ទះស្នាក់នៅរបស់ពួកគេ ដូចជាការមានបន្ទប់ទឹកផ្ទាល់ខ្លួននោះទេ ទោះបីជាពួកគេបានរស់នៅក្នុងសិប្បកម្មនោះអស់រយៈពេលជាងមួយទសវត្សរ៍មកហើយក្តី ។



អ្នកផ្តល់បទសម្ភាសរាយការណ៍អំពីភាពនឿយហត់ ទន់ខ្សោយ ក្តៅខ្លួន ឈឺក្បាល បញ្ហាក្រពះ ផ្តាសាយនិងគ្រុនក្តៅ អារម្មណ៍ស្ត្រេស និងពិបាកក្នុងការគេង ។

លក្ខខណ្ឌការងាររួមចំណែកបង្កឱ្យមានការឈឺស្កាត់ និងរបួស ។ អ្នកផ្តល់បទសម្ភាសរាយការណ៍អំពីភាពនឿយហត់ ទន់ខ្សោយ ក្តៅខ្លួន ឈឺក្បាល បញ្ហាក្រពះ ផ្តាសាយនិងគ្រុនក្តៅ អារម្មណ៍ស្ត្រេស និងពិបាកក្នុងការគេង ។ កម្មករស្រីម្នាក់បានប្រាប់ថាឪពុករបស់ខ្លួនបានពិការភ្នែកបន្ទាប់ពីធ្វើការនៅក្បែរឡឥដ្ឋដោយមិនមានឧបករណ៍ការពារអស់រយៈពេលជាច្រើនឆ្នាំ ។ កម្មករមួយចំនួនបានរាយការណ៍អំពីគ្រោះថ្នាក់ជាយថាហេតុផ្សេងៗក្នុងឧស្សាហកម្មនេះ ដូចជាគ្រោះថ្នាក់បាត់បង់អវយវៈដែលបានកើតឡើងជាយូរឆ្នាំមកហើយ ។

លទ្ធភាពទទួលបានការថែទាំសុខភាពនាពេលថ្មីៗនេះកាន់តែពិបាក ដោយសារម្ចាស់សិប្បកម្មផលិតឥដ្ឋបានបន្ថយចំនួនប្រាក់កម្ចីដល់កម្មករ ។ ឧទាហរណ៍ថា កម្មករម្នាក់ដែលមានអាការៈឈឺចាប់ ទទួលបានកម្ចីបន្ថែមច្រើនបំផុតត្រឹមតែ ១០០ ០០០រៀល (ប្រមាណ ២៥ ដុល្លារអាមេរិក) ប៉ុណ្ណោះ ដែលមិនគ្រប់គ្រាន់សម្រាប់ថ្លៃ ព្យាបាលនោះទេ ។ ថ្វីត្បិតតែត្រូវថែទាំសុខភាព គាត់នៅតែបន្តធ្វើការព្រោះគ្រួសាររបស់គាត់ត្រូវបានម្ចាស់សិប្បកម្មរារាំង មិនឱ្យធ្វើការនៅកន្លែងផ្សេង ដូចនេះគ្មានប្រាក់ចំណូលផ្សេងក្រៅពីនេះ ។ ការកាត់បន្ថយកម្ចីមានន័យថា កម្មករកាន់តែមិនចងជាប់ទៅនឹងសិប្បកម្មផលិតឥដ្ឋដោយសារបំណុល ប៉ុន្តែការលុបចោលបំណុលជាបន្ទាន់ គឺត្រូវការជាពិសេសនៅក្នុងបរិបទនេះ ។

លទ្ធភាពទទួលបានការថែទាំសុខភាពនាពេលថ្មីៗនេះ **កាន់តែពិបាក** ។

អាជ្ញាធរមូលដ្ឋាន ក៏បានបដិសេធផ្តល់ឱ្យកម្មករមួយចំនួននូវប័ណ្ណក្រីក្ររបស់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដែលជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយដ៏តិចក្នុងការទទួលបានការគាំពារសង្គមដែលនៅមានកម្រិតនៅកម្ពុជា ។ ឧទាហរណ៍ អាជ្ញាធរមូលដ្ឋានដែលនៅក្បែរសិប្បកម្មផលិតឥដ្ឋមួយ បានប្រាប់កម្មករឱ្យស្នើសុំប័ណ្ណនេះពីអាជ្ញាធរនៅស្រុកកំណើតរបស់ពួកគេ ហើយអាជ្ញាធរនៅស្រុកកំណើតរបស់ពួកគេបានប្រាប់ថាមិនអាចផ្តល់ប័ណ្ណនេះឱ្យដោយសារពួកគេបានធ្វើចំណាកស្រុកទៅកន្លែងផ្សេង ។ នៅទីតាំងមួយផ្សេងទៀត កម្មករម្នាក់បានទៅរកមេភូមិក្បែរសិប្បកម្មផលិតឥដ្ឋជាច្រើនលើកដើម្បីស្នើសុំប័ណ្ណ ក៏ប៉ុន្តែសំណើរបស់កម្មករតែងតែមិនត្រូវបានអើពើ ។



## ឥដ្ឋត្រូវបានទិញភាគច្រើនដោយគម្រោងអភិវឌ្ឍន៍បុរី

អង្គការលីកាដូ បានជជែកជាមួយកម្មករ ម្ចាស់សិប្បកម្ម និងអ្នកដឹកជញ្ជូនឥដ្ឋ ដើម្បីកំណត់ឱ្យដឹងថានរណាជាអ្នកទិញឥដ្ឋ ។ ឥដ្ឋត្រូវបានគេប្រាប់ឱ្យដឹងថាភាគច្រើនទិញដោយបុរី នៅរាជធានីភ្នំពេញ ហើយគេបានលើកឡើងឈ្មោះគម្រោងបុរីចំនួនប្រាំ ដោយសារបុរីទាំងនោះគឺជាគម្រោងដែលនៅតែបន្តសំណង់ទោះជាមានលក្ខណៈតិចតួចក្តី ។ អ្នកផ្តល់ចម្លើយផ្សេងទៀតបានប្រាប់ឱ្យដឹងថាឥដ្ឋលក់ទៅឱ្យឈ្មួញចែកចាយកណ្តាល ឬដាក់លក់ក្បែរសិប្បកម្មផលិតឥដ្ឋឱ្យទៅគម្រោងសំណង់ខ្នាតតូច ឬឯកជន ។

អង្គការលីកាដូ មិនអាចផ្ទៀងផ្ទាត់បញ្ជាក់ថាឥដ្ឋដែលផលិតក្រោមការបញ្ចាំខ្លួនដោះបំណុល ឬដោយពលកម្មកុមារ ត្រូវបានលក់ទៅឱ្យគម្រោងសាងសង់ជាក់លាក់ណាមួយឡើយ ។ ទោះជាយ៉ាងនេះក្តី បើសិនជាគិតអំពីការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារដែលកើតមានយ៉ាងទូលំទូលាយនៅក្នុងឧស្សាហកម្មផលិតឥដ្ឋ វាស្ទើរតែមិនអាចទៅរួចក្នុងការអះអាងថា មានគម្រោងសាងសង់ណាមួយ ដែលប្រើប្រាស់ឥដ្ឋដោយមិនកើតចេញពីអំពើរំលោភបំពានលើសិទ្ធិមនុស្សនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់ខ្លួន នោះទេ ។

**ស្ទើរតែមិនអាចទៅរួចក្នុងការអះអាងថា មានគម្រោងសាងសង់ណាមួយ ដែលប្រើប្រាស់ឥដ្ឋដោយមិនកើតចេញពីអំពើរំលោភបំពានលើសិទ្ធិមនុស្សនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់ខ្លួន ។**



# សេចក្តីសន្និដ្ឋាន

ការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារនៅតែមានជាទូទៅដដែលនៅសិប្បកម្មផលិតឥដ្ឋកម្ពុជា ។ ភស្តុតាងគាំទ្រលើអះអាងនេះ ត្រូវបានគេលើកបង្ហាញម្តងហើយម្តងទៀតអស់រយៈពេលជាច្រើនឆ្នាំមកហើយ ក៏ប៉ុន្តែត្រូវបានច្រានចោលជាមួយនឹងការបដិសេធមិនទទួលស្គាល់ ការសំងំស្ងៀម ឬការធ្វើអធិការកិច្ចដែលគ្មានប្រសិទ្ធិភាពពីអាជ្ញាធររដ្ឋ វិស័យឯកជន និងតួអង្គអន្តរជាតិ ។ ជាលទ្ធផល កម្មករសិប្បកម្មផលិតឥដ្ឋបន្តជាប់អន្ទាក់ រស់នៅ និងធ្វើការក្នុងស្ថានភាពប្រកបដោយគ្រោះថ្នាក់ និងការកេងប្រវ័ញ្ច ហើយមានឱកាសទាបដែលពួកគេអាចរួចផុតពីស្ថានភាពនៃទាសភាពសម័យទំនើបទាំងនេះ ។

ការថមថយនៃវិស័យសំណង់បច្ចុប្បន្ននេះ គឺជាឱកាសមួយសម្រាប់ផ្លាស់ប្តូរឧស្សាហកម្មផលិតឥដ្ឋនៅកម្ពុជា ។ ឧស្សាហកម្មនេះ គួរតែកំណត់ដោយប្រាក់ឈ្នួល និងលក្ខខណ្ឌការងារត្រឹមត្រូវ មិនមែនដោយការផ្តល់កម្ចី និងការបង្ខិតបង្ខំនោះទេ ដើម្បីអាចលុបបំបាត់ទាសភាពសម័យទំនើប និងពលកម្មកុមារបាន ។

**ការថមថយនៃវិស័យសំណង់បច្ចុប្បន្ននេះ គឺជាឱកាសមួយសម្រាប់ផ្លាស់ប្តូរឧស្សាហកម្មផលិតឥដ្ឋនៅកម្ពុជា ។**

# អនុសាសន៍

គួរអង្គក្នុងវិស័យសំណង់ និងអចលនទ្រព្យ ក្រុមហ៊ុនសំលៀកបំពាក់ម៉ាកអន្តរជាតិ សមាជិកសហគមន៍អន្តរជាតិ និងសាធារណជនទាំងអស់ គួររួបរួមគ្នាស្នើសុំឱ្យរាជរដ្ឋាភិបាល និងទាមទារឱ្យម្ចាស់សិប្បកម្មលុបចោលការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារនៅតាមសិប្បកម្មផលិតឥដ្ឋ ។ ការធានាដូចខាងក្រោមទាំងអស់ត្រូវមានជាបន្ទាន់៖

▶▶▶ **លុបចោលបំណុលរបស់កម្មករសិប្បកម្មផលិតឥដ្ឋជាបន្ទាន់ដើម្បីបញ្ចប់ការបញ្ចាំខ្លួនដោះបំណុល ។**

- ម្ចាស់សិប្បកម្មផលិតឥដ្ឋ ត្រូវលុបចោលជាបន្ទាន់នូវបំណុលរបស់កម្មករទាំងអស់ ។ កម្មករទាំងអស់ ត្រូវតែត្រូវទទួលបានការអនុញ្ញាតពីម្ចាស់សិប្បកម្ម ឱ្យចាកចេញពីសិប្បកម្ម ទៅធ្វើការនៅកន្លែងផ្សេង ដែលស្របនឹងគោលការណ៍សិទ្ធិការងារ និងសេរីភាពក្នុងការជ្រើសរើសការងារ ដោយអនុលោមតាមច្បាប់ការងារ ។

- រាជរដ្ឋាភិបាល ត្រូវពង្រឹងការអនុវត្តច្បាប់ស្តីពីការជួញដូរមនុស្ស និងច្បាប់ស្តីពីការងារ ដោយផ្តន្ទាទោសជនដែលត្រូវបានរកឃើញថានៅតែប្រព្រឹត្ត និងសមគំនិតប្រព្រឹត្តបទល្មើសនៃទាសភាពបំណុល ។

▶▶▶ **ធានាលក្ខខណ្ឌការងារត្រឹមត្រូវ ប្រាក់ឈ្នួលសមរម្យ និងការគាំពារសង្គមសម្រាប់កម្មករសិប្បកម្មផលិតឥដ្ឋ ។**

- រាជរដ្ឋាភិបាល ត្រូវបង្កើតឱ្យមានប្រាក់ឈ្នួលអប្បបរមាសមរម្យផ្លូវការ សម្រាប់កម្មករសិប្បកម្មផលិតឥដ្ឋ ហាមឃាត់ប្រព័ន្ធគិតប្រាក់ឈ្នួលតាមចំនួនដុំឥដ្ឋ និងធានាថាគ្រប់កម្មករសិប្បកម្មផលិតឥដ្ឋទទួលបានកិច្ចសន្យាការងារដោយមានការការពារក្រោមច្បាប់ការងារ ។

- រាជរដ្ឋាភិបាល ត្រូវបង្កើនលទ្ធភាពទទួលបានការថែទាំសុខភាពសម្រាប់គ្រប់គ្នា និងធានាលក្ខណៈជាប្រព័ន្ធថាគ្រប់បុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ទទួលបានប័ណ្ណក្រីក្រ និងរបបសន្តិសុខសង្គម ។

- អង្គការក្នុងស្រុក និងអន្តរជាតិ ត្រូវគាំទ្រកម្មករសិប្បកម្មផលិតឥដ្ឋក្នុងការបង្កើត និងពង្រឹងសហជីព ។

▶▶▶ **ហាមឃាត់ការងារទាំងឡាយណា ដែលធ្វើដោយកុមារក្រោមអាយុ ១៨ឆ្នាំ នៅក្នុងផលិតកម្មឥដ្ឋ ។**

- រាជរដ្ឋាភិបាល ត្រូវពង្រឹងបទបញ្ញត្តិដែលមានស្រាប់ និងហាមដាច់ខាតនូវការងារទាំងផ្លូវការ និងក្រៅផ្លូវការក្នុងដំណើរការនៃផលិតកម្មឥដ្ឋ ដែលធ្វើដោយកុមារក្រោមអាយុ ១៨ឆ្នាំ ដូចដែលបានធ្វើឡើងដោយហាមឃាត់គ្រប់ទម្រង់ទាំងអស់នៃពលកម្មកុមារនៅក្នុងវិស័យដោះគ្រាប់មីន រ៉ែ និងការងារយកថ្ម នៅក្នុងប្រកាសលេខ ១០៦ ស្តីពីការហាមឃាត់កុមារធ្វើការងារនៅកន្លែងការងារប្រកបដោយគ្រោះថ្នាក់ ។

▶▶▶ បញ្ឈប់ការផុតសំណល់ក្រណាត់របស់ឧស្សាហកម្មកាត់ដេរ នៅតាមសិប្បកម្មផលិតឥដ្ឋ ។

- ក្រុមហ៊ុនសំលៀកបំពាក់ម៉ាកអន្តរជាតិ ដែលទទួលបានផលិតផលខ្លួនពីប្រទេសកម្ពុជា ត្រូវធ្វើការត្រួតពិនិត្យ ស្របតាមគោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ សេចក្តីណែនាំ OECD សម្រាប់ក្រុមហ៊ុនពហុជាតិទៅលើការធ្វើធុរកិច្ចប្រកបដោយការទទួលខុសត្រូវ និងយន្តការផ្សេងទៀត ដើម្បីវាយតម្លៃ ការពារ កាត់បន្ថយ និងជួសជុលរាល់ហានិភ័យដែលបង្កឡើងដោយផលិតផល និងសំណល់របស់ខ្លួន ដោយបង្កផលប៉ះពាល់ដល់សិទ្ធិមនុស្ស ឬបរិស្ថាន ។
- ក្រសួងបរិស្ថាន ត្រូវចុះពិនិត្យសិប្បកម្មផលិតឥដ្ឋ និងពង្រឹងការដាក់ពិន័យចំពោះការដុតមិនត្រឹមត្រូវនៃសំណល់ឧស្សាហកម្មកាត់ដេរ យោងតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង ឆ្នាំ១៩៩៩ និងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦ ។

▶▶▶ បង្កើតប្រព័ន្ធផ្តល់វិញ្ញាបនបត្រមួយដែលមានឯករាជ្យភាព និងមានធនធានគ្រប់គ្រាន់ ដើម្បីឱ្យក្រុមហ៊ុនអភិវឌ្ឍន៍នៅកម្ពុជាអាចរកទិញឥដ្ឋ "ស្អាត" ពីសិប្បកម្មដែលបានលុបបំបាត់ពលកម្មដោះបំណុល ពលកម្មកុមារ និងការដុតសំណល់ក្រណាត់ ។

- តួអង្គអន្តរជាតិដូចជាអង្គការពលកម្មអន្តរជាតិ និងភ្នាក់ងាររបស់អង្គការសហប្រជាជាតិផ្សេងទៀត និងតួអង្គក្នុងវិស័យឯកជន ដូចជាអ្នកទិញឥដ្ឋ សភាពាណិជ្ជកម្មអាមេរិកនៅកម្ពុជា និងសភាពាណិជ្ជកម្មសហភាពអឺរ៉ុបនៅកម្ពុជា ត្រូវសហការជាមួយរាជរដ្ឋាភិបាល បង្កើតប្រព័ន្ធអធិការកិច្ច និងវិញ្ញាបនបត្រឯករាជ្យមួយសម្រាប់ឥដ្ឋ ដែលផលិតដោយគ្មានអំពើរំលោភបំពានលើសិទ្ធិមនុស្ស ។

▶▶▶ ពង្រឹង និងអនុវត្តយន្តការច្បាប់អន្តរជាតិទៅលើក្រុមហ៊ុនបរទេសណា ដែលបង្កឱ្យមានការរំលោភសិទ្ធិមនុស្ស នៅក្នុងគ្រប់កន្លែងនៃខ្សែសង្វាក់ផលិតកម្មរបស់ខ្លួន ។

- រដ្ឋាភិបាលបរទេស ត្រូវតែអនុម័ត និងអនុវត្តនូវបទដ្ឋានច្បាប់មួយចំនួនទៅលើក្រុមហ៊ុនដែលប្រតិបត្តិការនៅក្នុងដែនយុត្តាធិការរបស់ខ្លួន ដែលក្រុមហ៊ុនទាំងនោះចូលរួមចំណែក ឬមានពាក់ព័ន្ធដោយផ្ទាល់ទៅលើពលកម្មកុមារ ការបញ្ចាំខ្លួនដោះបំណុល និងផលប៉ះពាល់អវិជ្ជមានទៅលើសិទ្ធិមនុស្ស និងបរិស្ថានផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា តាមរយៈការទំនាក់ទំនងធុរកិច្ចរបស់ខ្លួន ។

www.licadho-cambodia.org